

# ការរំលោភយកដីធ្លី និងភាពក្រីក្រនៅកម្ពុជា:
# ការអភិវឌ្ឍក្លែងក្លាយ

"សកម្មភាពរុះរើលំនៅឋាន...ពុំមែនជាការបណ្តេញចេញទេ
ប៉ុន្តែជាការខិតខំប្រឹងប្រែងសម្អាតទីតាំង ដើម្បីអភិវឌ្ឍ"

ប្រសាសន៍ ឯកឧត្តម ម៉ាន់ ឆឿន
អភិបាលរងរាជធានីភ្នំពេញ

របាយការណ៍ លីកាដូ
ខែឧសភា ឆ្នាំ២០០៩


លីកាដូ
សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# ការរំលោភយកដីធ្លី និងភាពក្រីក្រនៅកម្ពុជា៖
# ការអភិវឌ្ឍក្លែងក្លាយ

របាយការណ៍ លីកាដូ

ខែឧសភា ឆ្នាំ២០០៩

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្ស នៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំ២ពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែក ច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរក ព័ត៌មានវិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ ( សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស )
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១ ទូរសារ: (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦
អ៊ីមែល: contact@licadho-cambodia.org គេហទំព័រ: http://www.licadho-cambodia.org/

# មាតិកា

**បុព្វកថា** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **១**

ការបដិសេធរបស់រាជរដ្ឋាភិបាល ---------------------------------------------------------៥

**កម្ពុជា៖ ជម្លោះដណ្តើមដីធ្លី** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៩**

ចំនួនគ្រួសាររងគ្រោះដោយករណីដីធ្លី ដែលឃ្លាំមើលដោយអង្គការលីកាដូ ចន្លោះឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ --------------------------------------------------------------------- ១០

ករណីដីធ្លី ដែលបានឃ្លាំមើលដោយអង្គការលីកាដូ ចន្លោះឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ តាមទីតាំង និងចំនួនគ្រួសាររងគ្រោះ --------------------------------------------------------- ១១

ករណីរំលោភយកដី និងការបណ្តេញចេញដោយបង្ខំមួយចំនួន នៅរាជធានីភ្នំពេញពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៩---------------------------------------------------------------------- ១៥

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ របាយការណ៍នៅភូមិអណ្តូង------------------------------ ១៨

**សម្បទានដីសង្គមកិច្ច** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **១៩**

ករណីសិក្សា៖ កុយ ចិន្តា----------------------------------------------------------------២១

ផលប្រយោជន៍ទទួលបានពីការអភិវឌ្ឍតំបន់ដីក្រហម ----------------------------------------២៦

**សម្បទានដីសេដ្ឋកិច្ច** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **២៧**

ករណិសិក្សា : ក្រុមហ៊ុន ស៊ី អាយ វី នៅខេត្តក្រចេះ--------------------------------- ៣៣

**ការពាក់ព័ន្ធរបស់យោធានៅក្នុងការរំលោភយកដី និង ការបណ្តេញដោយបង្ខំ~~~~~~~~~~៣៥**

ការពាក់ព័ន្ធរបស់យោធាកងយោធពលខេមរភូមិន្ទ ក្នុងការរំលោភលើប្រជាពលរដ្ឋ ទាក់ទងនឹងបញ្ហាដីធ្លី ដែលអង្គការលីកាដូបានស៊ើបអង្កេត ក្នុងឆ្នាំ២០០៨ ពីខែមករា ឆ្នាំ២០០៨ ដល់ ខែមករា ឆ្នាំ២០០៩ --៣៨

ករណីសិក្សា : តាកែន ខេត្តកំពត -------------------------------------------------៤៣

**សេចក្តីសន្និដ្ឋាន** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៤៤**

**អនុសាសន៍** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៤៤**

# បុព្វកថា

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ គឺជាសម័យសោកនាដកម្មដ៏គួរឱ្យរន្ធត់មួយដែលអាចនិយាយបានថា កម្ពុជាកំពុងរងគ្រោះ "ពីជម្ងឺឆ្លង" នៃបញ្ហារំលោភយកដីធ្លីដែលប្រព្រឹត្តដោយពួកអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច។ ជម្ងឺឆ្លងនេះ បានឈានទៅដល់ការបាត់បង់លំនៅឋាន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះយ៉ាងច្រើនឥតគណនា។

ស្ថិតិនានា ដ៏គួរឱ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ បានបង្ហាញដូចខាងក្រោម។

- នៅក្នុងខេត្ត-ក្រុង ចំនួន ១៣ ដែលលីកាដូបានចុះធ្វើការ-ប្រហែលជិតពាក់កណ្ដាលប្រទេស ប្រជាពលរដ្ឋ ជាងពីរសែនប្រាំម៉ឺននាក់ បានទទួលរងផលប៉ះពាល់ដោយការរំលោភយកដីធ្លី និងបណ្ដេញចេញពីលំនៅឋាន ដោយបង្ខំចាប់តាំងពីឆ្នាំ២០០៣ កន្លងមក។
- នៅរាជធានីភ្នំពេញ ប្រជាពលរដ្ឋចំនួន ១៣៣,០០០ នាក់ - ជាង ១០% នៃចំនួនប្រជាពលរដ្ឋសរុបត្រូវបានបណ្ដេញចេញពីលំនៅឋានដោយបង្ខំ ចាប់តាំងពីឆ្នាំ១៩៩០[១]។
- នៅឆ្នាំ២០០៨ យោងតាមរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ប្រជាពលរដ្ឋកម្ពុជា ១៥០,០០០ នាក់ទៀត បានប្រឈមមុខនឹងការប្ដូរទីតាំង ទៅរស់នៅកន្លែងតាំងទីលំនៅថ្មី នៅទូទាំងប្រទេស[២]។
- នៅឆ្នាំ២០០៤ គេបានប៉ាន់ប្រមាណថា ម្ចាស់ដីពី ២០% ទៅ ៣០% បានកាន់កាប់ដី ៧០%នៃទំហំដីសរុប ទូទាំងប្រទេស ហើយ៤០%នៃប្រជាពលរដ្ឋក្រីក្របំផុត កាន់កាប់ដីត្រឹមតែ ១០%។ ៤៥% នៃគ្រួសារនៅតំបន់ជនបទ គ្មានដីធ្លី ឬ ស្ទើរតែគ្មាន[៣]។

---

[១] របាយការណ៍ស្របគ្នា-ក្រុមការងារស្ដីពីដីធ្លី និងលំនៅឋាន: *សិទ្ធិដីធ្លី និងលំនៅឋាននៅកម្ពុជា* ខែមេសា ឆ្នាំ២០០៩ មាននៅក្នុងគេហទំព័រ: http://www.cohchr.org/store/attachments/Land%20and%and%20Housing%Rights%20in%20Cambodia%20(final).pdf

[២] របាយការណ៍អង្គការលើកលែងទោសអន្តរជាតិ: *ការបំបាត់សិទ្ធិ-ការបណ្ដេញចេញដោយបង្ខំពីលំនៅឋាននៅកម្ពុជា* ខែកុម្ភៈ ឆ្នាំ២០០៨។ មាននៅក្នុងគេហទំព័រ: http://www.amnestyusa.org/document.php?id=ENGASA230022008&lag=e

[៣] ធនាគារពិភពលោក: *ការវាយតម្លៃយែនឌ័រកម្ពុជា-ចំណែកសមរម្យសម្រាប់ស្ត្រី* ខែមេសា ឆ្នាំ២០០៤ មាននៅក្នុងគេហទំព័រ: http://go.worldbank.org/IVGO944NY0

***"យើងកំពុងធ្វើការអភិវឌ្ឍទីក្រុង.... គោលបំណងសំខាន់ គឺដើម្បីកាត់បន្ថយភាពក្រីក្រ"***

ប្រសាសន៍ ឯកឧត្តម ម៉ាន់ ឈឿន ក្នុងពេលបណ្តេញប្រជាពលរដ្ឋចេញនៅរាជធានីភ្នំពេញឆ្នាំ២០០៥[៤]

រដ្ឋាភិបាលតែងតែដោះសារជានិច្ច ដោយម្តងនិយាយយ៉ាងនេះ ហើយក្រោយមកនិយាយយ៉ាងនោះ ពេលត្រូវបណ្តេញប្រជាពលរដ្ឋដោយបង្ខំចេញពីលំនៅឋាន ដែលពួកគេបានកាន់កាប់រស់នៅអស់រយៈពេលជាច្រើនឆ្នាំមកហើយ រួចបញ្ជូនឱ្យទៅរស់នៅតំបន់ឆ្ងាយៗ ខ្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដើម្បីរស់នៅ ព្រមទាំងបាត់បង់ដីស្រែចម្ការ សម្រាប់ទ្រទ្រង់គ្រួសារ និងបន្តឱ្យកូនចៅជំនាន់ក្រោយ-
តើនេះជាការចាំបាច់សម្រាប់ "ការអភិវឌ្ឍឬ"។

មានការសង្ស័យខ្លះៗ ថាដីមួយចំនួននៅកម្ពុជាត្រូវបានទទួលការអភិវឌ្ឍជាវិជ្ជមានសម្រាប់តែបុគ្គលមានអំណាច និងក្រុមហ៊ុនឯកជនទាំងឡាយដែលបានទិញដីល្អៗ ក្នុងតម្លៃថោក ឬ ទទួលបានដោយគ្មានចំណាយសោះ ក៏ដូចមន្ត្រីរាជរដ្ឋាភិបាលមួយចំនួនបានទទួលផលចំណេញពីការដោះដូរដីទាំងនោះ។

ចំពោះបញ្ហានេះ គេសង្កេតឃើញមានភស្តុតាងតិចតួចបំផុត ដែលប្រជាពលរដ្ឋកម្ពុជាធម្មតាបានទទួលចំណេញពីការរឹបអូសយកដីដ៏ធំរបស់គេ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋណាដែលត្រូវបានបណ្តេញចេញសុទ្ធតែឥតបានទទួលផលចំណេញអ្វីទាល់តែសោះ ហើយលើសពីនេះទៅទៀត ពួកគេត្រូវប្រឈមមុខនឹងការបាត់បង់ការងារ និងចំណូលសម្រាប់ចិញ្ចឹមគ្រួសារ ប៉ះពាល់ដល់ផ្នែកសុខភាព កង្វះខាតការអប់រំ និងផលវិបាកផ្សេងៗជាច្រើនទៀត ដែលផ្ទុយស្រឡះទៅនឹងការសន្យាអភិវឌ្ឍន៍ជាសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានបង្ហាញនៅក្នុងគោលដៅនានា ដូចជា "គោលដៅអភិវឌ្ឍន៍សហស្សវត្ស" ជាដើម។

គ្មានសញ្ញាណាមួយដែលបង្ហាញថា អាជ្ញាធរកម្ពុជាបានកាត់បន្ថយការរំលោភយកដី និងការបណ្តេញប្រជាពលរដ្ឋដោយបង្ខំចេញពីលំនៅឋានឡើយ នេះគឺជាការប្រព្រឹត្តផ្ទុយស្រឡះពីច្បាប់កម្ពុជាតែម្តង។ រដ្ឋាភិបាលនៅតែ បន្តផ្តល់សម្បទានដីសេដ្ឋកិច្ចដោយខុសច្បាប់ និងលាក់ការសម្ងាត់បិទជិតមិនឱ្យសាធារណៈជនណាអាចដឹងបានឡើយ ហើយជួនកាលមានទំហំធំៗលើសពី ១០,០០០ ហិកតា ដែលច្បាប់បានកំណត់ថែមទៀត។

[៤] *បេសកជនអង្គការសហប្រជាជាតិមានប្រសាសន៍ថា ការបណ្តេញប្រជាពលរដ្ឋចេញ គឺជាការដាក់ទណ្ឌកម្មដល់ប្រជាពលរដ្ឋក្រីក្រ* កាសែត ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៥។

***"ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេស និងកាត់បន្ថយភាពក្រីក្រ ខ្ញុំបានដាក់ពាក្យស្នើសុំការអនុញ្ញាត ពីអាជ្ញាធរខេត្តរតនគីរី ដើម្បីដាំដើមកៅស៊ូនៅលើដី"***

នេះជាប្រសាសន៍របស់ពាណិជ្ជករស្ត្រីម្នាក់ ឈ្មោះ គាត កុល្យាណី ដែលបានលើកឡើងនៅក្នុងបណ្តឹងប្តឹងមកលើក្រុមមេធាវីតំណាងប្រជាពលរដ្ឋនៅក្នុងជម្លោះដីធ្លីដ៏ធំមួយនៅភូមិគងយុ ឆ្នាំ២០០៧[៥] ។

***"ប្រជាពលរដ្ឋបាននិយាយថា ពួកគាត់ខានបានចូលទៅរកបន្លែ និងបេះផ្លែឈើពីព្រៃ ដែលធ្លាប់ទៅរកពីមុនៗទៀតហើយ ថែមទាំងគ្មានដីគ្រប់គ្រាន់ប្រើប្រាស់ទៅអនាគត និងមិនអាចលែងគោ ក្របីឱ្យស៊ីស្មៅបាន ដោយសេរីដូចមុនទេ បើគោ ក្របីចូលចម្ការកៅស៊ូនឹងត្រូវគេចាប់ ។ កុមារមិនបានទៅរៀន ដោយត្រូវជួយឃ្វាលគោក្របី ។"***

ប្រសាសន៍លោក យ៉ាស់ ហ្គាយ តំណាងពិសេសរបស់អង្គការសហប្រជាជាតិអំពីបញ្ហាភូមិគងយុ ឆ្នាំ២០០៨[៦] ។

សម្បទានដីសង្គមកិច្ច នៅតែបន្តកើតឡើងដោយខុសច្បាប់ ។ តាមពិតគ្មានដីសម្បទានសង្គមកិច្ចណាមួយ បានអនុវត្តត្រឹមត្រូវតាមច្បាប់ទេ ហើយវិធីនេះ ត្រូវបានប្រើប្រាស់ដើម្បីលួចដីពីប្រជាពលរដ្ឋក្រីក្រមិនមែនដើម្បីផ្តល់ដីឱ្យប្រជាពលរដ្ឋទេ ។

យោធាកម្ពុជា នៅតែបន្តពាក់ព័ន្ធក្នុងសកម្មភាពបណ្តេញប្រជាពលរដ្ឋចេញ ដែលជាការផ្ទុយនឹងច្បាប់ ព្រមទាំងបានចូលរួមពាក់ព័ន្ធក្នុងការរំលោភយកដី សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ តុលាការកម្ពុជា ក៏នៅតែបន្តការពារផលប្រយោជន៍អ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច មិនខ្វល់ពីភស្តុតាងច្បាប់ភូមិបាល និងបទបញ្ញត្តិផ្សេងៗ អនុវត្តន៍ការបណ្តេញប្រជាពលរដ្ឋក្នុងខណៈដែលពុំទាន់សម្រេចថាអ្នកណាជាម្ចាស់កម្មសិទ្ធិនៅឡើយ ហើយចាប់អ្នកហ៊ានតវ៉ាដាក់ពន្ធនាគារទៀតផង ។ លើសពីនេះទៀតជាការបង្ហាញការពិតឱ្យឃើញថា ការបណ្តេញចេញទាំងនេះ ពិតជាការដណ្តើមយកដីមានតម្លៃ មិនមែនដើម្បីយកដីធ្វើការអភិវឌ្ឍទេ ដោយសង្កេតឃើញថា ទីតាំងជាច្រើនដែលបានបណ្តេញប្រពលរដ្ឋចេញកាលពីឆ្នាំកន្លងទៅថ្មីៗនេះ ម្ចាស់ដីថ្មី ក៏នៅតែពុំទាន់ធ្វើការអភិវឌ្ឍណាមួយទាល់តែសោះ ។

ចំពោះរឿងនេះ រាជរដ្ឋាភិបាលលើកឡើងថា គ្មានបញ្ហាទេ ។

---

[៥] ការបកប្រែក្រៅផ្លូវការ ។

[៦] របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ថ្លែងទៅកាន់មហាសន្និបាត អ.ស.ប ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨។




*យុទ្ធសាស្ត្រអភិវឌ្ឍន៍ចតុកោណរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជា ។*

*សហគមន៍ដីក្រហមដែលត្រូវបានបណ្តេញចេញកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩ ។*

## ការបដិសេធរបស់រាជរដ្ឋាភិបាល

ទោះបីជាមានការខ្វល់ខ្វាយកាន់តែខ្លាំងឡើងៗ និងមានការរិះគន់កន្លងមកពីសំណាក់សង្គមស៊ីវិលកម្ពុជា និងសហគមន៍អន្តរជាតិក៏ដោយរាជរដ្ឋាភិបាលកម្ពុជា នៅតែបរិយាយការបដិសេធជាទូទៅថា រឿងដីធ្លីគ្មានបញ្ហាអ្វីគួរឱ្យព្រួយបារម្ភទេ គ្មានការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំពីលំនៅឋាន ហើយថែមទាំងស្តីបន្ទោស និងវាយប្រហារអ្នកណាដែលបានលើកឡើងពីបញ្ហានោះទៀតផង ។

***"គ្មានការបណ្តេញប្រជាពលរដ្ឋដោយបង្ខំ និងខុសច្បាប់ទាល់តែសោះ នៅកម្ពុជាទេ"***

ការឆ្លើយតបរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំពោះរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ដែលបានសរសេរអំពីការបណ្តេញ ចេញដោយបង្ខំ ឆ្នាំ២០០៨[៧] ។

ជាពិសេស ប្រតិកម្មរបស់រាជរដ្ឋាភិបាលឆ្លើយតបចំពោះប្រសាសន៍របស់លោក **មីលូនកាថារី** អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅឋាន ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជាកាលពីឆ្នាំ២០០៥ ហើយបានប្រទះឃើញ "អ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាចទិញដីពាសពេញប្រទេសនៅកម្ពុជា"[៨] ។ ជំនួសឱ្យការដោះស្រាយបញ្ហាកង្វល់ដែលបានលើកឡើងសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការវាយប្រហារចំៗទៅលើអ្នកនាំពាក្យពិសេស ដោយបានមានប្រសាសន៍តាមរយៈ សុន្ទរកថាសាធារណៈមួយថា "បុរសម្នាក់ជាតំណាងអង្គការសហប្រជាជាតិ ... គាត់គ្រាន់តែមកដើម្បីលុយតែប៉ុណ្ណោះ ។ គាត់ចាត់ទុកថាប្រជាពលរដ្ឋកម្ពុជា គឺជាចោរ"[៩] ។

នៅឆ្នាំ២០០៨ ពេលដែលអង្គការលើកលែងទោសអន្តរជាតិ បានចេញផ្សាយរបាយការណ៍ពិស្តារអំពីការបណ្តេញចេញដោយបង្ខំនៅកម្ពុជា រាជរដ្ឋាភិបាលបានឆ្លើយតបវិញដោយបដិសេធថា "គ្មានការបណ្តេញដោយបង្ខំ និងខុសច្បាប់កើតឡើងនៅកម្ពុជាទេ" ។ ហើយគួរឱ្យចម្លែកថែមទៀតនោះគឺ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ថា សហគមន៍បុរីកីឡា និងសហគមន៍ដីក្រហមដែលកំពុងស្ថិតក្រោមការគំរាមកំហែងនៅភ្នំពេញ ដែលបុគ្គលិកសិទ្ធិមនុស្សនានា បានកត់ត្រាទុកនូវអំពើរំលោភសិទ្ធិដីធ្លីរាប់មិនអស់ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនោះ ថាប្រជាពលរដ្ឋមាន "ការសប្បាយចិត្ត" ចំពោះ

---

[៧] សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨។

[៨] ព័ត៌មាន BBC: *កម្ពុជា "កំពុងរងគ្រោះ ដោយវិបត្តិដីធ្លី"* ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ។

[៩] កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៥។

វិធានការរបស់រាជរដ្ឋាភិបាលទៅវិញ[១០]។ (មួយឆ្នាំប៉ុណ្ណោះបន្ទាប់ពីក្រសួងការបរទេសចេញសេចក្ដីថ្លែងការណ៍ ប្រជាពលរដ្ឋដែលនៅសេសសល់ក្នុងសហគមន៍ដីក្រហម ត្រូវបានបណ្ដេញចេញពោរពេញទៅដោយហិង្សា ដែលនេះជាឧទាហរណ៍នៃការបណ្ដេញចេញដោយបង្ខំមួយ ដែលរាជរដ្ឋាភិបាលអះអាងថាមិនដែលកើតឡើងសោះ)។ ស្របពេលដែល ឯកឧត្ដម ហោ ណាំបូរ៉ា ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅទីក្រុងឡុងដ៍ ដែលជាអ្នកនាំសារក្នុងការវាយប្រហារ បានចោទប្រកាន់អង្គការលើកលែងទោសអន្ដរជាតិថា "បាននិយាយបំភ្លើសការពិត" ថែមទាំងចោទប្រកាន់អ្នកស្រាវជ្រាវអង្គការនេះថា "ជាអ្នកផ្សងព្រេង" ដោយជំនួសឱ្យការឆ្លើយតបចំពោះព័ត៌មានរិះគន់យ៉ាងពិស្ដារនៅក្នុងរបាយការណ៍ ទៅជានិយាយ លើកអំពីសហគមន៍ក្រុមអ្នកផ្ដល់ជំនួយអន្ដរជាតិ និងការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលទៅវិញ[១១]។

ឯកឧត្ដម ឯកអគ្គរាជទូត បានបន្ដធ្វើស្រដៀងគ្នានេះដែរ ក្នុងឆ្នាំ២០០៩ ពេលដែលលោកឆ្លើយតប ចំពោះរបាយការណ៍របស់អង្គការ គ្លូបបិល វិតណេស ស្ដីពីឧស្សាហកម្មធនធានធម្មជាតិក្រោមដីនៅកម្ពុជា ដែលជាការលើកឡើងអំពីការផ្ដល់ដីសម្បទានសង្គមកិច្ចគ្រប់ទីកន្លែងទៅឱ្យក្រុមហ៊ុនឯកជននានា ដោយអង្អាប់របាយការណ៍នោះថា ជារបាយការណ៍ "ឥតន័យ" ដោយអះអាងថាអង្គការនេះ គឺជាអង្គការ "ឆោតល្ងង់" ព្រមទាំងបញ្ជាក់ថា ក្រុមសហគមន៍អ្នកផ្ដល់ជំនួយដល់កម្ពុជា "ដឹងទាំងអស់អំពីវិធីដែលរាជរដ្ឋាភិបាលកម្ពុជាអនុវត្តការងារ និងការសន្យារបស់ខ្លួន ដើម្បីទទួលបានបទដ្ឋានដ៏ខ្ពស់បំផុតតាមលទ្ធភាពដែលអាច ធ្វើទៅបាន"[១២]។




*ជាការដោះស្រាយបញ្ហាឬ?*
*របៀបដែលរាជរដ្ឋាភិបាលកម្ពុជាឆ្លើយតបចំពោះរបាយការណ៍ស្ដីពីឧស្សាហកម្មធនធានធម្មជាតិក្រោមដីរបស់អង្គការ គ្លូបិល វិតណេស*

---

[១០] សេចក្ដីថ្លែងការណ៍ របស់អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្ដរជាតិ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨។

[១១] លិខិតរបស់ឯកឧត្ដម ហោ ណាំបូរ៉ា ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំចក្រភពអង់គ្លេស ផ្ញើជូនអ្នកស្រី ខាថារីន បាបឺ នាយក កម្មវិធីអាស៊ីប៉ាស៊ីហ្វិក នៃអង្គការលើកលែងទោសអន្ដរជាតិ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

***"សកម្មភាពរុះរើលំនៅឋាននៅសហគមន៍ដីក្រហម គឺពុំមែនជាការបណ្ដេញចេញទេ ប៉ុន្តែជាការខិតខំប្រឹងប្រែងសម្អាតទីតាំងដើម្បីធ្វើការអភិវឌ្ឍ តែប៉ុណ្ណោះ"***

*ប្រសាសន៍ឯកឧត្តម ម៉ាន់ ឈឿន ឆ្នាំ២០០៩*[១៣]

ប៉ុន្តែការឆ្លើយតបរបស់ បណ្ឌិត ស៊ា កុសល ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ អាចជាការឆ្លើយតបដ៏ធ្ងន់ធ្ងរមួយ ក្រោយពីទស្សនកិច្ចនៃតំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក យ៉ាស់ ហ្គាយ នៅកម្ពុជាកាលពីខែធ្នូ ឆ្នាំ២០០៧។ ក្នុងពេលធ្វើទស្សនកិច្ច ដែលផ្ដោតទៅលើបញ្ហាដីធ្លី និងលំនៅឋាន លោកសាស្ត្រាចារ្យ យ៉ាស់ ហ្គាយ បានព្រមានថា កម្ពុជាអាចប្រឈមមុខនឹងអស្ថេរភាពសង្គម ដោយសារតែ "**ការអភិវឌ្ឍ**" ដែលគ្មានការគ្រប់គ្រងត្រឹមត្រូវ។ លោក បណ្ឌិត ស៊ា កុសល បានឆ្លើយតបតាមរយៈលិខិតមួយច្បាប់ផ្ញើជូនលោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយចោទប្រកាន់លោកសាស្ត្រាចារ្យ យ៉ាស់ ហ្គាយ ថាបាន "ញុះញង់ប្រជាពលរដ្ឋកម្ពុជា ឱ្យក្រោកឡើងធ្វើបដិវត្តប្រឆាំងនឹងរាជរដ្ឋាភិបាល" (ដោយបានលើកឡើងនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌ "ការញុះញង់" ដែលតែងតែចោទប្រកាន់តំណាងសហគមន៍នានា ដែលក្រោកឡើងតវ៉ាប្រឆាំងការបណ្ដេញចេញ និងការរំលោភយកដីធ្លី)[១៤]។

រាជរដ្ឋាភិបាលបានព្រងើយកន្តើយចំពោះការព្រមានប្រកបដោយគ្រោះថ្នាក់។ អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិជាច្រើនបានគាំទ្រការសង្កេតឃើញរបស់លោក យ៉ាស់ ហ្គាយ[១៥]។ ទំនាក់ទំនងការផ្ទេរឈ្មោះដី និងទំនាស់ ត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់[១៦] និងគ្រោះថ្នាក់សម្រាប់កម្ពុជាត្រូវបានលើកឡើងម្ដងហើយម្ដងទៀត ហើយថ្មីៗបំផុត គឺបានលើកឡើងនៅក្នុងរបាយការណ៍ដែលចេញផ្សាយដោយ British Think-Tank កាលពីខែមីនា ឆ្នាំ២០០៩ កន្លងទៅនេះ ស្ដីពីគ្រោះថ្នាក់រាលដាលមកពី

---

[១២] សេចក្ដីប្រកាសព័ត៌មានរបស់ស្ថានទូតទីក្រុងឡុងដ៍៖ *ឯកអគ្គរាជទូតវាយបកថា "ឆោតល្ងង់" ទៅលើក្រុមដាក់សម្ពាធ* ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩។

[១៣] រាជធានី - *ក្រុមហ៊ុនអភិវឌ្ឍន៍បានរុះរើ ឈូសឆាយសហគមន៍ដីក្រហម* កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩។

[១៤] លិខិតរបស់បណ្ឌិត ស៊ា កុសល ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ ផ្ញើជូនលោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧។

[១៥] សូមអានឧទាហរណ៍ កម្ពុជា៖ *ក្រុមអង្គការសិទ្ធិមនុស្សឈានមុខ បានគាំទ្របេសកជនអង្គការសហប្រជាជាតិ* សេចក្ដីថ្លែងការណ៍រួមរបស់ HRW, AHRC, FORUM ASIA FIDH និង OMCT ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៧។

[១៦] សូមអានឧទាហរណ៍ បញ្ជាក់អំពី *ភាពកម្រ និងការតស៊ូក្នុងប្រទេសកំពុងអភិវឌ្ឍន៍* ដោយ កូលីន ខាល សារព័ត៌មានសាកលវិទ្យាល័យព្រីនសេតតុន ឆ្នាំ២០០៦។

វិបត្តិហិរញ្ញវត្ថុពិភពលោក ដោយកត្តាវិភាគមួយចំនួនដូចជា វិសមភាពសង្គម និងការធ្លាក់ចុះសេដ្ឋកិច្ច ព្រមទាំងបានសន្និដ្ឋានថា កម្ពុជា គឺជាប្រទេសដែលងាយរងគ្រោះជាទីបំផុតមួយនៅក្នុងពិភពលោក ចំពោះចលាចលសង្គម និងនយោបាយ[១៧] ។

***"រាជរដ្ឋាភិបាលបានលើកឡើងអំពីការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែតាមពិត គឺរដ្ឋាភិបាលកំពុងព្យាយាមលុបបំបាត់អ្នកក្រីក្រ ទៅវិញទេ ។ ពួកគេបានបំផ្លាញយើង ដោយការដណ្តើមយកដី ព្រៃឈើរបស់យើង ប្រជាពលរដ្ឋ ចំនួន ៧០% ត្រូវបាត់ផុត ទៅ ដូច្នេះមានតែប្រជាពលរដ្ឋចំនួន ៣០% ប៉ុណ្ណោះ ដែលនឹង រស់នៅតទៅទៀត ។ កាលពីក្នុងរបបប៉ុល ពត យើងដាច់ពោះ ស្លាប់ភ្លាមៗ ប៉ុន្តែយើងអាចរក្សាព្រៃឈើយើងបាន ។ នៅក្នុង របបប្រជាធិបតេយ្យ គឺគេទុកឱ្យយើងរស់នៅយ៉ាងលំបាក វេទនាក្នុងរយៈពេលយូរមុននឹងស្លាប់ ។ អំពើហិង្សា នឹងកើត មានពីព្រោះយើងមិនចង់ស្លាប់ទេ"***

នេះជាសម្តីរបស់ប្រជាពលរដ្ឋម្នាក់ ដែលទទួលផលប៉ះពាល់ដោយសម្បទានដីសង្គមកិច្ច[១៨] ។

ការមិនទទួលស្គាល់បញ្ហាដោយចេតនា ដែលធ្វើឱ្យប្រទេសជាតិកំពុងប្រឈមមុខនឹងបញ្ហាបែបនេះ មិនបានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាសប្បាយចិត្ត ហើយទៅអនាគតវាក៏អាចធ្វើឱ្យអាជ្ញាធរកម្ពុជាមិនសប្បាយចិត្តដូចគ្នាដែរ ។ គ្មានការសង្ស័យទេ ចំពោះភាពស្មុកស្មាញការគ្រប់គ្រងសេដ្ឋកិច្ច ហើយប្រទេសនេះបានទទួលរងដោយកត្តាខាងក្រៅជាច្រើន ដែលខ្លួនមិនអាចគ្រប់គ្រងបាន ខណៈនោះកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពជោគវាសនាមួយ ដែលត្រូវចាត់វិធានការជាជំហានៗ ដើម្បីដោះស្រាយការលំបាកដែលប្រជាពលរដ្ឋកំពុងជួបប្រទះបន្ទាន់ ។ វិធានការជាដំបូងហើយសំខាន់បំផុតគឺការកាត់បន្ថយនូវកំណើនការរំលោភយកដីដែលបានកើតឡើងនិងការលួចកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចក្រោមផ្លាក "អភិវឌ្ឍន៍" ។

[១៧] របាយការណ៍ពិសេសរបស់ក្រុមភ្នាក់ងារអ្នកសេដ្ឋវិទូៈ *ការបង្កឧបសគ្គរារាំង* ខែមីនា ឆ្នាំ២០០៩ ។ របាយការណ៍នេះ បានចាត់ទុកថា កម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី ៤ នៃសន្ទស្សន៍អស្ថេរភាពនយោបាយទូទៅ ប្រសើរជាងប្រទេស ហ្ស៊ីមបាវេ ឆាដ និងកុងហ្គោ តែប៉ុណ្ណោះ ។

[១៨] ទស្សនៈសិទ្ធិមនុស្សៈ *ដីសម្បទានសេដ្ឋកិច្ចនៅៈ* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០៤ មាននៅក្នុងគេហទំព័រៈ http://cambodia.ohchr.org/EN/report_thematic.html

# កម្ពុជា: ជម្លោះដណ្តើមដីធ្លី

ការដកហូតដីដោយបង្ខំ ជាបញ្ហាដែលមានយូរយារណាស់មកហើយនៅកម្ពុជា។ ប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ គេសង្កេតឃើញមានការផ្ទុះឡើងនូវបញ្ហានេះ ព្រមទាំងមានអំពើហិង្សាថែមទៀតផង។

ចំពោះករណីដែលលីកាដូ បានធ្វើការឃ្លាំមើលចន្លោះឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ មានប្រជាពលរដ្ឋចំនួន ៥៣,៧៥៨ គ្រួសារ បានក្លាយជាជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងដីធ្លី រួមទាំងការរំលោភយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ យោងតាមស្ថិតិជាផ្លូវការស្តីពីទំហំគ្រួសារមធ្យម ឃើញថា មានប្រជាពលរដ្ឋរងគ្រោះច្រើនជាង ពីរសែនប្រាំម៉ឺននាក់ ដែលរងការរំលោភដីធ្លី នេះបង្ហាញត្រឹមតែ ១៣ ខេត្ត-ក្រុង ដែលលីកាដូកំពុងធ្វើការតែប៉ុណ្ណោះ[១៩]។

[១៩] ផ្អែកទៅតាមទំហំគ្រួសាជាមធ្យមដែលដកស្រង់ចេញពីវិទ្យាស្ថានជាតិស្ថិតិកម្ពុជា ក្នុងគេហទំព័រ http://statistic.org ប្រជាពលរដ្ឋកម្ពុជាប្រមាណ ២៦១.៧០៥ នាក់ បានរងផលប៉ះពាល់នៅក្នុងខេត្តគោលដៅរបស់ លីកាដូ។ នេះមិនបានគិតដល់ជនរងគ្រោះដោយការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ ដែលមានសមាជិកគ្រួសារច្រើនជាងចំនួនសមាជិកគ្រួសារជាមធ្យមផង។

## ចំនួនគ្រួសាររងគ្រោះដោយករណីដីធ្លី ដែលឃ្លាំមើលដោយអង្គការលីកាដូ ចន្លោះឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨



## ករណីដីធ្លី ដែលបានឃ្លាំមើលដោយអង្គការលីកាដូ ចន្លោះឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ តាមទីតាំង និងចំនួនគ្រួសាររងគ្រោះ





*កន្លែងបណ្តេញប្រជាពលរដ្ឋសំបុកចាប គឺនៅតែមិនទាន់អភិវឌ្ឍន៍នៅឡើយ រហូតដល់ខែឧសភា ឆ្នាំ២០០៩។*

ជនល្មើសនៅក្នុងករណីរំលោភដីធ្លីសុទ្ធតែខុសៗគ្នា។ ករណីខ្លះជារឿងទំនាស់ដីសាមញ្ញជាមួយអ្នកជិតខាង។ ករណីខ្លះទៀត ពាក់ព័ន្ធជាមួយផលប្រយោជន៍របស់អ្នកមានអំណាចជាមួយមន្ត្រីរាជរដ្ឋាភិបាល និងសមាជិកនៃកងកម្លាំងប្រដាប់អាវុធជាដើម ជាពិសេសយោធាដែលតែងតែស្ថិតនៅពីក្រោយខ្នងការដណ្តើមដីមានតម្លៃពីអ្នកកាន់កាប់ដី និងម្ចាស់ស្របច្បាប់។ ប៉ុន្តែ បញ្ហាមួយដែលកាន់តែស្មុកស្មាញខ្លាំងឡើងនោះ គឺរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនធំៗចូលរួមពាក់ព័ន្ធ ជួនកាលក្រុមហ៊ុនខ្លះត្រូវបានជួយឧបត្ថម្ភគាំទ្រដោយវិនិយោគបរទេស ដែលចង់បានចំណេញពីការរឹបអូសដី ដើម្បីកាត់បន្ថយការចំណាយ និងមិនគិតគូរអំពីសិទ្ធិរបស់គ្រួសារក្រីក្រ ដែលពឹងផ្អែកលើដីទាំងនោះដើម្បីសង់លំនៅឋាន និងជីវភាពរស់នៅប្រចាំថ្ងៃឡើយ។

ទោះបីជាមានទំហំខុសៗគ្នាក៏ដោយ ក៏ករណីស្ទើរតែទាំងអស់មានចំណុចដូចគ្នាខ្លះៗដែរ ដែលចំណុចទាំងនោះគឺ ការមិនគោរពច្បាប់កម្ពុជាដែលនៅជាធរមាននៅឡើយ (ជាពិសេសច្បាប់ភូមិបាលឆ្នាំ២០០១) ការប្រើប្រាស់កងកម្លាំងសន្តិសុខដោយខុសច្បាប់ ដើម្បីគំរាមកំហែង និងបណ្តេញប្រជាពលរដ្ឋដែលរស់នៅលើដីដោយស្របច្បាប់ និងការប្រើប្រាស់និតិវិធីតុលាការរំលោភយកដីកម្មសិទ្ធិដោយខុសច្បាប់ និងការបំភិតបំភ័យដល់អ្នកដែលហ៊ានក្រោកឡើងតវ៉ា។ ករណីចាប់ និងឃុំឃាំងខ្លួនដោយបំពានចំពោះអ្នកដែលហ៊ានជំទាស់តវ៉ាបញ្ហារំលោភយកដី នៅតែបន្តរីករាលដាលឥតឈប់ឈរ ទោះបីជាសម្តេចនាយករដ្ឋមន្ត្រីបានសន្យាថា ដោះលែងប្រជាពលរដ្ឋដែលជាប់ឃុំឃាំងដោយសារបញ្ហាដីធ្លី នៅឆ្នាំ២០០៦ ក៏ដោយ[២០]។ នៅ ចុងឆ្នាំ២០០៨ លីកាដូ បានរកឃើញថា យ៉ាងតិច៤៣ ករណី ដែលមានអ្នកតវ៉ាករណីជំលោះដីធ្លីដែលកំពុងជាប់ពន្ធនាគាររងចាំសវនាការ ឬអ្នកដែលបានកាត់ទោសឱ្យជាប់ពន្ធនាគារផ្អែកទៅលើការចោទប្រកាន់មិនច្បាស់លាស់ ដែលស្ទើរតែទាំងអស់ត្រូវបានចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបទញុះញង់ជាដើម។

[២០] ពិន ស៊ីសុវណ្ណ : គីម សុខា-*សម្តេចនាយករដ្ឋមន្ត្រី បញ្ជាឱ្យដោះលែងអ្នកទោសដោយទំនាស់ដីធ្លី* កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦។

ទោះបីជាការរំលោភទាំងនោះស្ថិតក្រោមផ្លាក "អភិវឌ្ឍន៍" ក៏ដោយ ពិសេសបញ្ហានេះបញ្ជាក់ឱ្យឃើញថា មានករណីជាច្រើននៃការបណ្តេញសហគមន៍ គឺដើម្បីយកដីធ្វើគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្ម តែតាមពិតគេសង្កេតឃើញថា មានការអភិវឌ្ឍតិចតួចជាទីបំផុត ឬ គ្មានសោះតែម្តងនៅលើដីទាំងនោះ។

ឧទាហរណ៍ នៅខែមិថុនា ឆ្នាំ២០០៦ នៅចំកណ្តាលរដូវភ្លៀង ប្រជាពលរដ្ឋចំនួន ១,៣៨០ គ្រួសារដែលបានជួលផ្ទះនៅក្នុងសហគមន៍សំបុកចាប នៅរាជធានីភ្នំពេញ ត្រូវបានបណ្តេញចេញដឹកយកទៅដាក់នៅជាយក្រុង ចម្ងាយ ២២ គីឡូម៉ែត្រ ក្នុងភូមិមួយហៅថាភូមិអណ្តូង ដែលជាវាលស្រែសុទ្ធតែទឹក គ្មានបង្គន់ គ្មានផ្ទះ និងគ្មានទឹកស្អាតទទួលទាន។ មួយខែមុននេះ គ្រួសារដែលជាម្ចាស់ផ្ទះចំនួន ១,៣៦៧ គ្រួសារ ត្រូវបានបណ្តេញចេញពីសហគមន៍សំបុកចាប ឱ្យទៅរស់នៅកន្លែងមួយផ្សេងទៀត។ ដីសហគមន៍សំបុកចាបនៅក្បែរមាត់ទន្លេ នៅជិតមន្ទីររដ្ឋសភាជាតិ ជាដីមានតម្លៃខ្ពស់ជាទីបំផុត ត្រូវបានផ្តល់ឱ្យទៅក្រុមហ៊ុនឈ្មោះ ស៊ូ ស្រ៊ុន ដើម្បីធ្វើការអភិវឌ្ឍពាណិជ្ជកម្ម ប៉ុន្តែ ៣ ឆ្នាំ ក្រោយមក ដីដែលមានទំនាស់នោះ នៅតែមិនទាន់មានការអភិវឌ្ឍដដែល ហើយមានព្រៃដុះពាសពេញលើដីទាំងអស់។


*កន្លែងបណ្តេញចេញប្រជាពលរដ្ឋ នៅតែមិនទាន់អភិវឌ្ឍន៍ រហូតមកដល់ខែឧសភា ឆ្នាំ២០០៩ នេះ*

ស្រដៀងគ្នានេះដែរ នៅខែមិថុនា ឆ្នាំ២០០៦ ប្រជាពលរដ្ឋ ១៦៨ គ្រួសារ ត្រូវបានបណ្តេញចេញដោយបង្ខំ ចេញពីសហគមន៍ក្បែរមន្ទីរពេទ្យព្រះមុនីវង្ស ជិតផ្សារធំថ្មី ក្នុងរាជធានីភ្នំពេញ ដើម្បីយកដីឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប របស់លោក គិត ម៉េង (ដែលជាម្ចាស់ក្រុមហ៊ុនទូរស័ព្ទម៉ូប៊ីតែល និងធនាគារ ANZ) សម្រាប់អភិវឌ្ឍន៍ពាណិជ្ជកម្ម។ ប៉ុន្តែ ៣ ឆ្នាំ ក្រោយមក ដីដ៏មានតម្លៃនេះ ត្រូវបានប្រើប្រាស់ជាទីធ្លាសម្រាប់ចត និងលាងរថយន្តទៅវិញ។

ដោយសង្កេតឃើញយ៉ាងច្បាស់ថាគ្មានចេតនាធ្វើការអភិវឌ្ឍជាបន្ទាន់លើដីទាំងនោះ ក្នុងចំណោមទីតាំងរៀបរាប់ខាងលើ នោះការបណ្តេញប្រជាពលរដ្ឋឱ្យចេញពីដីទាំងនោះដោយបង្ខំ វាជារឿងហួសហេតុពេកខណៈនៅសល់ពេលរាប់ឆ្នាំងណោះ ដើម្បីចរចារដោះស្រាយឱ្យបានសមរម្យសម្រាប់គ្រួសារទាំងនោះ។

| ករណីរំលោភយកដី និងការបណ្តេញចេញដោយបង្ខំមួយចំនួន នៅរាជធានីភ្នំពេញពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៩ | | | | | | | |
|---|---|---|---|---|---|---|---|
| **ក្រុមហ៊ុន** | **ទីតាំង** | **គ្រួសាររងគ្រោះ** | **កាលបរិច្ឆេទ បណ្តេញ** | **គម្រោងប្រើប្រាស់ដី** | **ស្ថានភាពដី** | **ស្ថានភាពជនរងគ្រោះ** | **ផ្សេងៗ** |
| **ស៊ូ ស៊្រុន** | សំបុកចាប ទន្លេបាសាក់ ចំការមន | ១.៣៦៧ (ម្ចាស់ផ្ទះ) ១.៣៨០ (អ្នកជួល) | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៦ | មជ្ឈមណ្ឌលពាណិជ្ជកម្ម | គ្មានការអភិវឌ្ឍនៅឡើយ | ទីតាំងថ្មីពីភ្នំពេញទៅត្រពាំងអញ្ចាញ ចំងាយ ២០ គីឡូម៉ែត្រ។ ទីតាំងថ្មីពីភ្នំពេញទៅភូមិអណ្តូង ចម្ងាយ ២២ គីឡូម៉ែត្រ។ មានប្រជាពលរដ្ឋច្រើនជាង ១០០០ គ្រួសារ រស់នៅគ្មានជម្រកសមរម្យ។ | ៨នាក់បានជាប់ឃុំឃាំង ហើយក្រោយមក ៣ នាក់ ត្រូវបានជាប់ពន្ធនាគារ បន្ទាប់ពីការបណ្តេញចេញដោយបង្ខំ នៅខែមិថុនា ឆ្នាំ២០០៦។ |
| The Royal Group | មន្ទីរពេទ្យមុនីវង្ស ផ្សារថ្មី៣ ដូនពេញ | ១៦៨ | ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ | មិនដឹងគោលបំណងពាណិជ្ជកម្ម | មិនទាន់អភិវឌ្ឍ (បច្ចុប្បន្នក្លាយជាកន្លែងចត និងលាងរថយន្ត) | ទីតាំងថ្មី ពីភ្នំពេញទៅអង្គស្នួល ចម្ងាយ ៣០ គីឡូម៉ែត្រ ក្រោយមកប្រជាពលរដ្ឋស្ទើរតែទាំងអស់ បានត្រឡប់មកនៅសំណង់ក្រីក្រក្នុងទីក្រុងវិញ។ | ស្ត្រី ៣ នាក់ចូលពេទ្យ ស្ត្រីមានផ្ទៃពោះម្នាក់ ត្រូវឆក់ដោយដំបងឆក់ក្នុងពេលបណ្តេញដោយបង្ខំ។ |
| SOKIMEX | ចុងជ្រោយចង្វា ជ្រោយចង្វា ឫស្សីកែវ | ១៣២ | ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ | គ្មាន | កំពុងសាងសង់អគារស្នាក់នៅយ៉ាងប្រណិត | ទីតាំងថ្មីនៅត្រពាំងអញ្ចាញ | បណ្តេញដោយបង្ខំដើម្បី "លប់បំបាត់គ្មានសណ្តាប់ធ្នាប់ក្នុងសង្គម ដើម្បីការពារបរិស្ថានអនាម័យ សុខភាពសាធារណៈ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | និងកែលំអរទីក្រុង"។ |
| | ដីក្រហម ទន្លេបាសាក់ ចំការមន | ១,៤៦៥ | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩ | ការអភិវឌ្ឍលំនៅឋាន នៅនឹងកន្លែង និងកសាងអគារពាណិជ្ជកម្ម (ផ្ទះល្វែងនិងអគារការិយាល័យ) | មិនទាន់អភិវឌ្ឍន៍ | គ្រួសារនៅសល់ត្រូវបណ្តេញដោយបង្ខំទៅនៅភូមិដំណាក់ត្រយឹង ចម្ងាយ ២០គីឡូម៉ែត្រ ពីទីក្រុង | គ្រួសារភាគច្រើន ទីបំផុតព្រមទទួលយកសំណង/ផ្ទះថ្មី។ ជាង ៤០០គ្រួសារ ត្រូវបានបណ្តេញដោយបង្ខំ រួមទាំងម្ចាស់ផ្ទះ អ្នកជួល និងអ្នកលក់ផង។ |
| | បូរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា | ១.៤០០ | កំពុងបណ្តេញ | អភិវឌ្ឍន៍លំនៅឋាននៅនឹងកន្លែង/ ក្រសួងអប់រំ /អភិវឌ្ឍន៍ពាណិជ្ជកម្ម | ពាក្នុងចំណោមអគារ ១០ ត្រូវបានសាងសង់រួចរាល់។ ក្រសួងទេសចរណ៍ កំពុងសាងសង់ដែល ផ្ទុយនឹងប្លង់គោល។ | ប្រហែល ១៦០គ្រួសារ ត្រូវបានបណ្តេញចេញពីផ្ទះ/៤២គ្រួសារត្រូវបានបណ្តេញចេញដោយបង្ខំ ទៅរស់នៅត្រពាំងអញ្ចាញឆ្នាំ២០០៧។ ជាង ១០០០គ្រួសារ កំពុងរងចាំការដោះស្រាយ ប្រសិនបើគ្រួសារទាំងនេះត្រូវបានបណ្តេញចេញ ឬផ្តល់ផ្ទះនៅទីតាំងនោះ។ | យ៉ាងតិច៤៧គ្រួសារ ភាគច្រើនអ្នកមានផ្ទុកមេរោគអេដស៍ កំពុងប្រឈមការបណ្តេញចេញឱ្យទៅនៅទួលសំបូរ ចម្ងាយ ២០ គីឡូម៉ែត្រ ពីភ្នំពេញ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ស៊ូ ស្រ៊ុន** | ក្រុម ៧៨ ទន្លេបាសាក់ ចំការមន | ១៤៦ | ជិត បណ្ដេញ ចេញ | មូលហេតុ ទំនាស់ចម្រុះគ្នា | សហគមន៍នៅកាន់កាប់នៅឡើយ | ៦៦គ្រួសារ នៅលើដីនោះនៅឡើយ រង់ចាំថ្ងៃបណ្ដេញចេញ | ស៊ូ ស្រ៊ុន អះអាងថា ប្រគល់ដីនេះឱ្យសាលារាជធានីដើម្បីកសាងផ្លូវ |
| CANADIA BANK PLC. | វីករាយ ទន្លេបាសាក់ ចំការមន | ២០៩ | ជិត បណ្ដេញ ចេញ | សហគមន៍ទំនើប | ប្រជាពលរដ្ឋកាន់កាប់ដីនោះនៅ ឡើយ | រង់ចាំថ្ងៃបណ្ដេញចេញ | កំពុងបូមខ្សាច់លប់ស្រះរបស់សហគមន៍ ខែឧសភា ឆ្នាំ២០០៩ ទោះជាមានការ តវ៉ាដោយអហិង្សាក៏ដោយ ។ |
| **អភិវឌ្ឍន៍ ហាស្សាន់** | រថភ្លើងក/ខ ស្រះចក ដូនពេញ ផ្សារដេប៉ូ III ទួលគោក | ៣២៥ | ជិត បណ្ដេញ ចេញ | អគារការិយាល័យ និងមណ្ឌលពាណិជ្ជកម្ម | សហគមន៍នៅកាន់កាប់នៅឡើយ | រង់ចាំថ្ងៃបណ្ដេញចេញ | ប្រធានក្រុមហ៊ុន ឧស្មាន់ ហាស្សាន់ ជារដ្ឋលេខាធិការក្រសួងការងារ |
|  **ភាពីម៉ិច (ស៊ូកាគូ)** | បឹងកក់ ទួលគោក និងដូនពេញ | ៤,២៥២ | ជិត បណ្ដេញ ចេញ | មជ្ឈមណ្ឌលពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ លំនៅឋាន និងលំហែកាយ | សហគមន៍នៅកាន់កាប់នៅឡើយ | រង់ចាំថ្ងៃបណ្ដេញចេញ | ជួលឱ្យក្រុមហ៊ុនស៊ូកាគូ ៩៩ ឆ្នាំ។ បឹងជាសម្បត្តិរដ្ឋគឺខុសច្បាប់ភូមិបាលឆ្នាំ២០០១ |

## គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ៈ របាយការណ៍នៅភូមិអណ្តូង

***តើប្រជាពលរដ្ឋ ១,៣៨០ គ្រួសារពីសហគមន៍សំបុកចាបដែលត្រូវបណ្តេញដោយបង្ខំទៅនៅភូមិអណ្តូងអាចជួយរដ្ឋាភិបាលសម្រេចបានគោលដៅសហស្សវត្សរ៍ដូចម្តេច?***

**គោលដៅទី២ៈ សម្រេចបានការអប់រំបឋមជាសកល**

*តាមអ្នកឃ្លាំមើលលីកាដូ បានប៉ាន់ប្រមាណថាក្នុងចំណោម ១,២០០ គ្រួសារ នៅភូមិអណ្តូងមិនត្រូវបានរដ្ឋាភិបាល ទទួលស្គាល់ជាផ្លូវការ ហើយកុមារតិចជាង ៤០% បានចូលរៀននៅសាលា ។*

**គោលដៅទី៣ៈ លើកកម្ពស់សមភាពយេនឌ័រ និងអំណាចស្ត្រី**

*អ្នកឃ្លាំមើលរាយការណ៍ថា ប្តីចុះចោលគ្រួសារមានអត្រាខ្ពស់ នៅអណ្តូង ដោយទុកឱ្យស្ត្រីចិញ្ចឹមគ្រួសារតែម្នាក់ឯង ។*

**គោលដៅទី១ៈ លុបបំបាត់ភាពក្រីក្រ និងការអត់ឃ្លានជាទីបំផុត**

*គ្រូពេទ្យលីកាដូ  ប៉ាន់ប្រមាណថា យ៉ាងតិចកុមារ ៥០% រស់នៅភូមិអណ្តុងទទួលរងគ្រោះដោយកង្វះជីវជាតិ ។*



**គោលដៅទី៤ៈ កាត់បន្ថយអត្រាមរណៈកុមារ**

*អត្រាទូទៅនៅអណ្តូងមិនបានដឹង ប៉ុន្តែគ្រូពេទ្យកត់សំគាល់ថា អត្រាមរណៈរបស់កុមារខ្ពស់ខុសពីធម្មតា ជាពិសេសបណ្តាលមកពីកង្វះជីវជាតិ  ជម្ងឺរបេង គ្រុនឈាម និងរាគរូស ។*

**គោលដៅទី៨ៈ បង្កើតដៃគូពិភពលោកដើម្បីអភិវឌ្ឍន៍**

*(បង្កើត និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ការងារសមរម្យ និងផលិតកម្មសម្រាប់យុវជន) ប្រជាពលរដ្ឋនៅអណ្តូងភាគច្រើនរកចំណូលបានតិចជាង ២ ដុល្លារអាមេរិកក្នុងមួយថ្ងៃ ដោយរើសអេតចាយ  ស៊ីឈ្នួលដកស្ទូង បោកគក់ ឬកម្មករសំណង់ ។*

**គោលដៅ ៥ៈ លើកកម្ពស់សុខភាពមាតា**

*គ្រូពេទ្យលីកាដូ ប៉ាន់ប្រមាណថាកុមារយ៉ាងតិច ៨%នៅភូមិអណ្តូងកើតមកមានជម្ងឺធ្ងន់ធ្ងរ បណ្តាលមកពីមាតាមានសុខភាពមិនល្អ ។*

**គោលដៅទី៧ៈ ធានាការពារបរិស្ថានឱ្យបានល្អ**

*(ពាក់កណ្តាលត្រឹមឆ្នាំ ២០១៥ សមាមាត្រនៃប្រជាពលរដ្ឋនៅមិនទាន់មានទឹកស្អាតប្រើប្រាស់នៅឡើយ) ការវិភាគទឹកនិងអនាម័យឆ្នាំ ២០០៨ បានរកឃើញថា គ្មានទឹកស្អាតប្រើប្រាស់ទេនៅភូមិអណ្តូង ហើយស្រះ និងអណ្តូងមានសារធាតុពុលក្នុងកម្រិតខ្ពស់ដែលមិនអាចទទួលយកបាន ។*

**គោលដៅទី៦ៈ ប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺផ្សេងៗទៀត**

*អ្នកជម្ងឺអេដស៍ ដែលត្រូវបណ្តេញទៅនៅអណ្តូងប្រឈមនឹងការលំបាកយ៉ាង ខ្លាំងក្នុងការព្យាបាលដែលពួកគេត្រូវការ ។ គ្រូពេទ្យលីកាដូ សង្កេតឃើញថាអត្រាជម្ងឺគ្រុនឈាមនៅតំបន់នោះ នៅតែខ្ពស់ជាងនៅភ្នំពេញ ៥០%  ។*

# សម្បទានដីសង្គមកិច្ច

នៅខែមីនា ឆ្នាំ២០០៣ យុទ្ធសាស្ត្រថ្មីមួយត្រូវបានផ្សព្វផ្សាយឡើងដើម្បីប្រយុទ្ធប្រឆាំងភាពក្រីក្រ និងភាពកង្វះដីធ្លី ហៅថា: **សម្បទានដីសង្គមកិច្ច។**

---

***"សម្បទានដីសង្គមកិច្ច" គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋ តាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ច ដល់ជនក្រីក្រ ដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។"***

មាត្រា ២ អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (ឆ្នាំ២០០៣)

---

អនុក្រឹត្យថ្មីនេះ ទោះបីជាមិនទាន់ល្អឥតខ្ចោះក៏ដោយ ក៏បានដាក់ចេញនូវក្របខណ្ឌច្បាប់ជាមូលដ្ឋានដើម្បីបែងចែកដីជូនប្រជាពលរដ្ឋក្រីក្រដែរ។ ក្នុងចំណោមបញ្ញត្តិទាំងនោះ មានបញ្ញត្តិមួយបានចែងអំពីការបង្កើតអង្គភាពអន្តរក្រសួង/នាយកដ្ឋាន ដែលជាអង្គភាពអាចផ្តល់ការយល់ព្រម និងគ្រប់គ្រងដីសម្បទានជំនួសឱ្យអង្គការនីតិប្រតិបត្តិក្នុងការអនុវត្តន៏ការងារនេះ។ បញ្ហានេះតម្រូវឱ្យមានព័ត៌មានលំអិត ស្តីពីម្ចាស់កម្មសិទ្ធិដីធ្លី គោលបំណងក្នុងការប្រើប្រាស់ដី និងប្រភេទនៃការបែងចែកដីដែលត្រូវដាក់ជូនទៅអង្គភាពមុននឹងមានការឯកភាព ព្រមទាំងកំណត់លក្ខខណ្ឌអំពីវិធីក្នុងការផ្សព្វផ្សាយផែនការទាំងនេះ។ នៅក្នុងករណីខុសពីធម្មតា ចំពោះផ្នែកណាមួយនៃនីតិប្បញ្ញត្តិរបស់កម្ពុជា គឺតម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍។ សម្បទានដីសង្គមកិច្ចថ្មីនេះ គឺជាកលល្បិចមួយបែប ដែលបែកចេញពីការរំលោភយកដី និងបណ្តេញចេញដោយបង្ខំ ដែលបានធ្វើពីមុនៗមក។

បួនខែក្រោយមក "សម្បទានដីសង្គមកិច្ច" លើកទីមួយត្រូវបានបង្កើតឡើង ដែលជាការបំភ្លេចចោលអនុក្រឹត្យនេះទាំងស្រុង។ មិនត្រឹមតែមិនបានអនុវត្តតាមដំណើរការផែនការណ៍ ការពិគ្រោះយោបល់ និងតម្លាភាពប៉ុណ្ណោះទេ ថែមទាំងមានលិខិតមួយយ៉ាងសាមញ្ញចេញពីទីស្តីការគណៈរដ្ឋមន្ត្រី ផ្ញើជូនអភិបាលរាជធានីភ្នំពេញ

ប្រកាសពីការ "ឯកភាព" សម្បទានដីសង្គមកិច្ច ដែលកាន់កាប់ដោយសហគមន៍ក្នុងក្រុងភ្នំពេញចំនួន ៤ គឺសហគមន៍បូរីកីឡា សហគមន៍ដីក្រហម ផ្លូវរថភ្លើង ក និងផ្លូវរថភ្លើង ខ។

ក្នុងរយៈពេល ៥ ឆ្នាំ កន្លងមកនេះ វាបានបង្ហាញយ៉ាងច្បាស់ថា គោលបំណងពិតរបស់សម្បទានដីសង្គមកិច្ច គឺពុំមែនដើម្បីផ្តល់ដី និងលំនៅឋានជូនប្រជាពលរដ្ឋក្រីក្រទេ គឺដើម្បីធ្វើឱ្យប្រជាពលរដ្ឋក្រីក្រទាំងនោះគ្មានលំនៅឋានរស់នៅទេវិញ ដោយបាត់បង់ដីដែលធ្លាប់រស់នៅ ហើយប្រែក្លាយដីទាំងអស់នោះទៅជាទ្រព្យសម្បត្តិឯកជនរបស់ក្រុមហ៊ុន ដើម្បីធ្វើជា **"គម្រោងអភិវឌ្ឍន៍"** បានចំណេញច្រើន។ រហូតមកដល់ពេលនេះ គេបានដេញប្រជា-ពលរដ្ឋចេញពីលំនៅឋានដោយបង្ខំនៅសហគមន៍បូរីកីឡា និងសហគមន៍ដីក្រហម ហើយប្រជាពលរដ្ឋនៅសេសសល់ក្នុងសហគមន៍ផ្លូវរថភ្លើង ក និង ខ គឺកំពុងធ្វើការជូនដំណឹងស្តី ពីការបណ្តេញចេញជាចុងក្រោយ។

ដោយរៀបចំឡើងដោយខុសច្បាប់ មើលទៅសំណើដើម្បីធ្វើសម្បទានដីបូរីកីឡា ហាក់ដូចជាសមហេតុផលម្យ៉ាងដែរ។ ក្រុមហ៊ុនឯកជនមួយឈ្មោះ (ភាពីម៉ិច) នឹងសាងសង់អគារផ្ទះល្វែងថ្មីនៅលើដី ដើម្បីចែកជូនប្រជា-ពលរដ្ឋចំនួន ១,៧៧៦ គ្រួសារ ដែលយោងតាមការសិក្សាជាផ្លូវការឱ្យដឹងថា គ្រួសារទាំងនោះ គឺជាម្ចាស់ផ្ទះ ឬ អ្នកជួលអស់រយៈពេលជាយូរឆ្នាំមកហើយ។ ជាថ្នូរនៃការសាងសង់អគារផ្ទះល្វែងនេះ ក្រុមហ៊ុនត្រូវទទួលបានដីមួយផ្នែកដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម។ បច្ចុប្បន្ននេះ ក្រសួងអប់រំដែលធ្លាប់បានប្រើប្រាស់ផ្នែកខ្លះនៃដីនោះតាំងពីយូរយារណាស់មកហើយ ក៏បានត្រឡប់មកប្រើប្រាស់តំបន់នោះវិញដែរ។

ជិត ៦ឆ្នាំ ក្រោយមក មានតែ ៣០% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ដែលបានទទួលផ្ទះរស់នៅតាមការសន្យានោះ ដែលពោរពេញទៅដោយអំពើពុករលួយកើតឡើងពាសវាលពាសកាល និងខ្វះតម្លាភាពនៅក្នុងដំណើរការនៃការបែងចែកនោះ។ ប្រជាពលរដ្ឋប្រហែល ១៦០ គ្រួសារ ត្រូវបានបណ្តេញចេញពីលំនៅឋានរបស់ខ្លួន ហើយពុំបានទទួលផ្ទះរស់នៅឡើយ រួមទាំង ២៥ គ្រួសារ ដែលត្រូវបានទទួលផ្ទះរស់នៅ យោងតាមដំណើរការនៃការពិនិត្យវាយតម្លៃរួមរបស់សាលារាជធានី និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានវាយតម្លៃកាលពី ២ ឆ្នាំ កន្លងទៅនេះ។ ចំណែកឯ ៤២ គ្រួសារ រួមទាំង ៥ គ្រួសារ ទៀតដែលត្រូវបានវិនិច្ឆ័យថា ត្រូវទទួលបានផ្ទះរស់នៅផងនោះ ប៉ុន្តែទីបំផុត បែរជាមិនបានទទួលទេវិញ ថែមទាំងត្រូវបណ្តេញចេញដោយហិង្សាថែមទៀត ដោយឱ្យទៅរស់នៅកន្លែងតាំងទីលំនៅថ្មីនៅភូមិត្រពាំងអញ្ចាញដែលមានចម្ងាយ ២០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ គ្រួសារសេសសល់ដែលត្រូវបានបណ្តេញរួចហើយ នៅតែបន្តរស់នៅទីនោះទៀតក្នុងខ្ទមតូចៗជាបណ្តោះអាសន្ន ដោយនៅមានសង្ឃឹមថានឹងបានទទួលផ្ទះរស់នៅដោយប្រការណាមួយ។ ហើយផ្តើមចេញពីការប្រើប្រាស់ដីដូចបានបញ្ជាក់ខាងលើនៅក្នុង

ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានបែងចែកដីទំហំ ៧.០០០ ម៉ែត្រការ៉េ នៅក្នុងទំហំដីទាំងនោះឱ្យក្រសួងទេសចរណ៍ ដើម្បីសាងសង់អគារថ្មីសម្រាប់ក្រសួងនេះ (ដោយក្រុមហ៊ុន ភាពីម៉ិច) រួមទាំងទីធ្លាចតរថយន្ត និងទីធ្លាលេងកីឡា សម្រាប់បុគ្គលិកក្រសួងផង។ ក្រោមការគំរាមកំហែងនាពេលបច្ចុប្បន្ន គឺប្រជាពលរដ្ឋប្រហែល ៤៧ គ្រួសារ ដែលភាគច្រើនជាអ្នកផ្ទុកមេរោគអេដស៍ ហើយដែលផ្ទះសម្បែងរបស់អ្នក ទាំងនោះត្រូវបានរុះរើចោលអស់ក្នុងឆ្នាំ២០០៧ ដើម្បីយកដីសាងសង់អគារផ្ទះស្នាក់នៅ។ ប្រជាពលរដ្ឋទាំងនោះកំពុងរស់ នៅក្នុងជម្រកបណ្ដោះអាសន្នលើដី ដែលមានដាក់ផ្លាកក្រសួងទេសចរណ៍ ហើយកំពុងរងគ្រោះដោយគេជិតបណ្ដេញចេញពីទីនោះហើយ។ គ្រួសារដែលផ្ទុកជម្ងឺអេដស៍ទាំងនោះ នឹងត្រូវបណ្ដេញឱ្យទៅនៅតំបន់ទីតាំងថ្មីដាច់ដោយឡែកមួយ នៅទួលសំបូរ ដែលមានចម្ងាយ ២០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដែលត្រូវបានអ្នកខ្លះហៅថាដូចជា "និគមអ្នកកើតឃ្លង់" ខ្ទះហេដ្ឋារចនាសម្ព័ន្ធសព្វបែបយ៉ាង ជាកន្លែងដែលអ្នកទាំងអស់នោះរស់នៅឆ្ងាយពីកន្លែងប្រកបរបរចិញ្ចឹមជីវិត និងឆ្ងាយពីមន្ទីរពេទ្យ ដែលធ្លាប់ទទួលថ្នាំព្យាបាលចាំបាច់ដើម្បីរស់បន្តទៅទៀត[២១]។

**ករណីសិក្សាៈ កុយ ចិន្តា**

ករណី កុយ ចិន្តា ស្ត្រីមេម៉ាយកូន ៥នាក់ ដែលបានមកជួលផ្ទះនៅបូរីកីឡាក្រោយពីប្ដីបានស្លាប់ទៅកាលពីឆ្នាំ ២០០០ កន្លងទៅនេះ ជាឧទាហរណ៍ជាក់ស្ដែងក្នុងករណីមួយចំនួនដែលបង្ហាញពីការបរាជ័យរបស់អាជ្ញាធរកម្ពុជា ក្នុងការបំពេញកាតព្វកិច្ចជាសីលធម៌ និងច្បាប់ចំពោះសម្បទានដីសង្គមកិច្ច។

វាជាការលំបាកណាស់ក្នុងការស្រមៃ ថានរណាម្នាក់មានលក្ខខណ្ឌគ្រប់គ្រាន់ស្របច្បាប់ជាងគេ ដែលអាចទទួលផ្ទះរស់នៅបានក្នុងតំបន់ដីសម្បទានសង្គមកិច្ចបូរីកីឡានោះ។



*អ្នកស្រីកុយ ចិន្តា និងផ្ទះរបស់គាត់ ដែលត្រូវគេរុះរើ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨*

---

[២១] ទីតាំងថ្មីបូរីកីឡា បង្កើតជានិគមអ្នកកើតឃ្លង់ សម័យថ្មី : អង្គការមិនមែនរដ្ឋាភិបាល កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨។ ចំពោះប្រវត្តិរឿងលំអិត សូមមើលបូរីកីឡាៈ *គម្រោងសាងសង់លំនៅឋានសង្គមកិច្ចកម្ពុជា ៥ ឆ្នាំ ទៅមុខ* របាយការណ៍សង្ខេបលីកាដូ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ អាចអាននៅក្នុងគេហទំព័រៈ http://www.licadho-cambodia.org/articles/20081219/ 84/index.html

លក្ខខណ្ឌនេះ ត្រូវបានឯកភាពរួមគ្នារវាងសាលាក្រុងភ្នំពេញ និង សហគមន៍បូរីកីឡា កាលពីខែកុម្ភៈ ឆ្នាំ២០០៤ រួមទាំងអ្នកជួលណាដែលបានរស់នៅក្នុងតំបន់បូរីកីឡាបាន ៣ឆ្នាំ ឬ លើសពីនេះ សុទ្ធតែត្រូវបានចាត់ទុកថាជាគ្រួសារមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានផ្ទះរស់នៅដែលសាងសង់នៅនឹងកន្លែង។ លើសពីនេះទៅទៀត អនុក្រិត្យស្តីពីសម្បទានដីសង្គមកិច្ចបានចែងថា នៅទីណាដែលមានគ្រួសារដាក់ពាក្យសុំច្រើនជាងចំនួនក្បាលដីដែលមាននោះ ត្រូវផ្តល់អាទិភាពឱ្យគ្រួសារណាដែលមេគ្រួសារជាស្ត្រី ហើយមានកូន ៦នាក់ ឬ លើសពីនេះបានទទួលដីមុនគេ[២២]។

ប៉ុន្តែ ចំពោះអ្នកស្រីកុយ ចិន្តា គ្មានអ្នកណាប្រាប់គាត់អំពីការធ្វើជំរឿនប្រជាពលរដ្ឋរស់នៅបូរីកីឡាដែលបានធ្វើកាលពីឆ្នាំ២០០៣ នោះទេ ហើយពេលកំពុងចុះឈ្មោះគ្រួសារទាំងនោះអ្នកស្រី ចិន្តា បានស្ថិតនៅកន្លែងធ្វើការឯណោះ។ ក្រៅពីការខកខានខាងលើនេះអ្នកស្រី ចិន្តា ក៏ពុំមានឯកសារគ្រប់គ្រាន់ដើម្បីបញ្ជាក់ដោយអាជ្ញាធរមូលដ្ឋានថាជាសមាជិកសហគមន៍តាំងពីឆ្នាំ២០០០ មកម្ល៉េះ ទោះបីជាមានការអះអាងបញ្ជាក់ពីអ្នកជិតខាង និងសាក្សីមួយចំនួន រួមទាំងអតីតប្រធានការងាររបស់គាត់ ដែលបានបញ្ជាក់ជាលាយលក្ខណ៍អក្សរផងដែរក៏ដោយ។



អ្នកស្រីកុយ ចិន្តា និងទ្រព្យសម្បត្តិរបស់គាត់ ខណៈពេលដែលក្រសួងទេសចរណ៍រៀបចំសម្ពោធ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨

នៅខែសីហា ឆ្នាំ២០០៨ អ្នកស្រីកុយ ចិន្តា បានឮពីអ្នកជិតខាងថា ក្រសួងទេសចរណ៍បំរុងរៀបចំធ្វើពិធីបញ្ចុះសីមា នៅក្នុងតំបន់បូរីកីឡា។ នាងហាក់ដូចជាមិនសូវខ្វល់ប៉ុន្មានទេអំពីបញ្ហានេះ រហូតដល់ថ្ងៃទី២៥ ខែសីហា ទើបកូនស្រីច្បងរបស់អ្នកស្រីបានទូរស័ព្ទប្រាប់ដោយនិយាយថា មានបុរស ៥ នាក់ កាន់ពូថៅ ញញួរ និង ដំបងគ្រប់ដៃចូលមកក្នុងផ្ទះ ហើយចាប់ផ្តើមរុះរើផ្ទះរបស់អ្នកស្រីគ្មានសល់។ ពេលនោះនាងបានប្រញាប់ប្រញាល់ត្រឡប់មកផ្ទះ នៅពេលអ្នកស្រីមកដល់ ការរុះរើនោះបានចប់សព្វគ្រប់រួចហើយ។

[២២] អនុក្រិត្យស្តីពីសម្បទានដីសង្គមកិច្ច (ឆ្នាំ២០០៣) មាត្រា ១១។

ទ្រព្យសម្បត្តិរបស់គ្រួសារអ្នកស្រី គេបានប្រមូលដាក់លើគ្រែមួយ ក្បែរដីដែលពីមុនជាផ្ទះរបស់នាង។ ពេល ដែលអ្នកស្រីសួរកម្មកររុះរើទាំងនោះថា តើនាងត្រូវទៅរស់នៅឯណាជាមួយកូន ៥ នាក់ គេបានប្រាប់គាត់ថា មិនអាចជួយបានទេ ដោយពួកគេគ្រាន់តែទទួលបញ្ជាឱ្យមករុះរើផ្ទះតែប៉ុណ្ណោះ។

អង្គការសិទ្ធិមនុស្សបានជួយផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់អ្នកស្រីកុយចិន្តា និងគ្រួសារ ហើយចាប់តាំងពីគេធ្វើការរុះរើមក គ្រួសារអ្នកស្រីបានរស់នៅក្នុងជម្រកបណ្តោះអាសន្នលើដីជិតផ្ទះរបស់អ្នកស្រីពីមុន។ ជម្រកបណ្តោះអាសន្ននោះគ្មានបង្គន់អនាម័យ ទឹកលិចតាមដំបូលពេលភ្លៀងធ្លាក់ម្តងៗ ដូច្នេះ អ្នកស្រី ចិន្តា និងកូនពីរនាក់កើតមានជម្ងឺផ្លូវដង្ហើម។ នាងនៅតែបន្តទាមទារផ្ទះរស់នៅមួយ នៅបូរីកីឡាតាមសិទ្ធិពេញលេញរបស់អ្នកស្រី ប៉ុន្តែអាជ្ញាធរនៅតែធ្វើព្រងើយកន្តើយចំពោះករណីរបស់គាត់។ ដោយការងារសាងសង់ចេះតែបន្តនៅលើទីតាំងក្រសួងទេសចរណ៍ថ្មី ហើយមើលទៅគ្មានសង្ឃឹមថានឹងបានទទួលផ្ទះរស់នៅដែលអ្នកស្រីត្រូវបាន នោះគ្រួសារអ្នកស្រី ចិន្តា រស់នៅក្នុងក្តីភិតភ័យជាប្រចាំ ដែលថ្ងៃណាមួយអ្នកស្រី និងកូនៗទាំងអស់នឹងត្រូវទៅរស់នៅជាមួយប្រជាពលរដ្ឋ ចំនួន ៤២ គ្រួសារ ដែលត្រូវបានអាជ្ញាធរបណ្តេញចេញដោយបង្ខំពីបូរីកីឡា ទៅកន្លែងតាំងទីលំនៅថ្មីនៅត្រពាំងអញ្ចាញ។

នៅខែតុលា ឆ្នាំ២០០៨ ប្រជាពលរដ្ឋ ៤២ គ្រួសារ ត្រូវបានបណ្តេញចេញពីបូរីកីឡាអស់ហើយ អ្នកខ្លះត្រូវកងរាជអាវុធហត្ថវាយដំ និងឆក់ដោយដំបងឆក់ក្នុងពេលបណ្តេញអ្នកទាំងនោះ ត្រូវបានអាជ្ញាធរអញ្ជើញឱ្យចូលរួមក្នុងពិធីប្រគល់ប័ណ្ណទទួលស្គាល់ម្ចាស់ដីឡូតិ៍ ដែលចែកដោយមន្ត្រីរាជរដ្ឋាភិបាល នៅត្រពាំងអញ្ចាញ។ ប័ណ្ណនេះ បានចែងយ៉ាងច្បាស់ថា ត្រូវបានចេញជូនប្រជាពលរដ្ឋ ដោយយោងតាមអនុក្រិត្យស្តីពីសម្បទានដីសង្គមកិច្ច។ វាជាការចំម្លែកខ្លាំងណាស់ចំពោះគ្រួសារក្រីក្រ ដែលត្រូវបានបង្ខំឱ្យចាកចេញពីផ្ទះរបស់ខ្លួនដែលជាដី



អ្នកទទួលប័ណ្ណម្ចាស់ដីឡូតិ៍ នៅត្រពាំងអញ្ចាញ ខែតុលា ឆ្នាំ២០០៨

សម្បទានសង្គមកិច្ចមួយ ហើយក្រោយមកត្រូវទៅរស់នៅលើដីសម្បទានសង្គមកិច្ចមួយផ្សេងទៀត។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
សាលាខណ្ឌដង្កោ
សង្កាត់

លេខ [redacted]

**បណ្ណទទួលស្គាល់ម្ចាស់ដីឡូត៍**

ឈ្មោះ [redacted] ភេទ [redacted] អាយុ [redacted] ឆ្នាំ សញ្ជាតិ [redacted] និងខាង [redacted] អាយុ [redacted] ...
កន្លងមកស្នាក់នៅភូមិ ... សង្កាត់ ... ខណ្ឌ ... រាជធានីភ្នំពេញ ...
បច្ចុប្បន្នបានទទួលដីឡូត៍លេខ [redacted] នៅភូមិត្រពាំងអញ្ចាញ ... សង្កាត់ត្រពាំងក្រសាំង ... រាជធានីភ្នំពេញ ។

**គំណត់សំគាល់ :**

១- យោងអនុក្រឹតលេខ ១៩ អ.ន.ក្រ.បក ចុះថ្ងៃទី១៩ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីដីសម្បទានសង្គមកិច្ច បណ្ណនេះហាមលក់ដូរ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយឱ្យអ្នកដទៃក្នុងរយៈពេល ០៥ឆ្នាំ គិតចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ ...

២-ក្នុងករណីល្មើសនិងចំណុចទី១ ខាងលើ សាលាក្រុងភ្នំពេញនឹងដកហូតយកដីនោះវិញ ដោយគ្មានល័ក្ខខ័ណ្ឌ ។

៣-ផុតរយៈពេល ០៥ឆ្នាំ រដ្ឋនឹងចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ជូនម្ចាស់កាន់កាប់ដើម្បីប្រើប្រាស់តទៅ ។

៤-ជនណាដែលប្រើប្រាស់បណ្ណនេះខុសគោលដៅ និងត្រូវទទួលទោសតាមច្បាប់កំណត់ ។

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ...

បានពិនិត្យត្រឹមត្រូវ មេឃុំសង្កាត់ | បានឃើញ ប្រធានភូមិ | ស្នាមមេដៃអ្នកទទួលដីឡូត៍

បណ្ណទទួលស្គាល់ម្ចាស់ដីឡូត៍ នៅត្រពាំងអញ្ចាញ ដែលបានចេញ យោងតាមអនុក្រឹត្យ សម្បទានដីសង្គមកិច្ច

បច្ចុប្បន្ននេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវទទួលភារកិច្ចឱ្យត្រួតពិនិត្យអនុក្រិត្យ មិនបានទទួលស្គាល់ថាត្រពាំងអញ្ចាញជា "**ដីសម្បទានសង្គមកិច្ច**" ទេ ហើយពិតណាស់ ទីស្តីការគណៈរដ្ឋមន្ត្រីក៏មិនបានទទួលស្គាល់ដែរ ក្នុងឆ្នាំ ២០០៤។

យោងតាមក្រសួងឱ្យដឹងថាដីសម្បទានសង្គមកិច្ចបច្ចុប្បន្ននេះ មានតែ ៣ កន្លែងប៉ុណ្ណោះ គឺមួយកន្លែងស្ថិតនៅក្នុង ខេត្តក្រចេះ មួយកន្លែងក្នុងខេត្តកំពង់ធំ និងនៅខេត្តកំពង់ចាម។ ហើយក៏គ្មានកន្លែងណាមួយក្នុងចំណោមកន្លែងទាំងនោះ ត្រូវបានបញ្ចប់នៅឡើយដែរ[២៣]។ ប្រជាពលរដ្ឋរស់នៅក្នុង "ដីសម្បទានសង្គមកិច្ច "តំបន់ដីក្រហម ក៏ទទួលវាសនាអាក្រក់ស្រដៀងគ្នានេះដែរ គឺដូចប្រជាពលរដ្ឋរស់នៅបូរីកីឡា ដែលមុនដំបូងគេសន្យាថាអភិវឌ្ឍន៍លំនៅឋាន នៅនឹងកន្លែង ដែលកសាងដោយក្រុមហ៊ុនឯកជន។ ប៉ុន្តែផែនការនេះ ត្រូវបានផ្លាស់ប្តូរដោយខុសច្បាប់ ទៅជាការផ្តល់លំនៅឋានក្រៅទីតាំង នៅភូមិដំណាក់ត្រយឹង ចម្ងាយ ២០ គីឡូម៉ែត្រ ទៅ

[២៣] លីកាដូ បានជួបជាមួយមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខែមេសា ឆ្នាំ២០០៩។

វិញ។ ក្រុមហ៊ុន ឯកជនមួយឈ្មោះថា សេវិនអិនជី និងអាជ្ញាធរមូលដ្ឋានបាន ចុះធ្វើយុទ្ធនាការហិង្សា និងការបំភិតបំភ័យ បង្ខិតបង្ខំ ដែលអូសបន្លាយពេលយ៉ាងយូរឱ្យ ប្រជាពលរដ្ឋ "ស្ម័គ្រចិត្ត" ចាកចេញពីដីក្រហម។ យុទ្ធនាការនោះរួមមានការប្ដឹងសមាជិកសហគមន៍ ដែលប្រឆាំងនឹងក្រុមហ៊ុនពីបទព្រហ្មទណ្ឌ។ ទោះបីជាគ្មានភស្តុតាងរួមទាំងការរំលោភលើនីតិវិធីព្រហ្មទណ្ឌជាច្រើនក៏ដោយ ក៏ក្នុងនោះ មនុស្សចំនួន ២១ នាក់ (រួមទាំងតំណាងសហគមន៍ ១០ នាក់) ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ហើយ ២ នាក់ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ។ ការបណ្ដេញដោយបង្ខំចុងក្រោយបង្អស់ គឺនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩ ដែលគេឃើញមានជាង ៤០០ គ្រួសារដែលនៅសល់ត្រូវបានបង្ខំ ឱ្យចេញទៅនៅកន្លែងតាំងទីលំនៅថ្មីហៅថា ដំណាក់ត្រយឹង។ គ្រួសារដែលជាម្ចាស់ផ្ទះ និងដី ត្រូវបានគេផ្ដល់ជម្រើស "ចាកចេញ ឬ យក" នូវផ្ទះមួយល្វែងដែលមាន ១ បន្ទប់នៅភូមិដំណាក់ត្រយឹង ហើយនៅសល់ ៣៣៥ គ្រួសារទៀត ដែលភាគច្រើនជាអ្នកជួល និងអ្នកមានតូបលក់ដូរនៅផ្សារ ត្រូវបានទុកឱ្យនៅក្រោមជម្រកតង់ ដែលបរិស្ថានជុំវិញគ្មានអនាម័យ។ មនុស្សគ្រប់គ្នាដែលរស់នៅទីតាំងឆ្ងាយៗបែបនេះ ប្រឈមនឹងបញ្ហាស្រដៀងគ្នាគឺ ការចំណាយច្រើនទៅលើការធ្វើដំណើរប្រកបរបរចិញ្ចឹមជីវិត ទៅសាលារៀន ទៅមន្ទីរពេទ្យ និងទៅរកអ្វីផ្សេងៗទៀត នៅទីក្រុងភ្នំពេញ។[២៤]

---

[២៤] ចំពោះព័ត៌មានបន្ថែមសូមមើល របាយការណ៍ដែលមានចំណងជើងថា *សេចក្ដីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* លីកាដូកាណាដា ខែមករា ឆ្នាំ២០០៨ *និងសុបិន្តអាក្រក់នៅដីក្រហម: ការបណ្ដេញចេញដោយបង្ខំនៅចំកណ្ដាលរាជធានីភ្នំពេញ* អត្ថបទរបស់លីកាដូ ខែកុម្ភៈ ឆ្នាំ២០០៩។ របាយការណ៍ទាំងពីរនេះមាននៅក្នុងគេហទំព័រ: http://www.licadho-cambodia.org

## ផលប្រយោជន៍ទទួលបានពីការអភិវឌ្ឍតំបន់ដីក្រហម

**សមាជិកសហគមន៍**



*អ្នកជួល និង អ្នកលក់ដូរនៅផ្សារត្រូវបានបញ្ជូនទៅតំបន់តាំងទីលំនៅថ្មី ដែលខ្វះហេដ្ឋារចនាសម្ព័ន្ធ ជាមូលដ្ឋាន ខ្វះទឹកស្អាត ខ្វះបង្គន់ ខ្វះសាលារៀន និង ខ្វះកន្លែងសំរាកព្យាបាលជំងឺ ។*

**តំណាងសហគមន៍**



*ការផ្តន្ទាទោសដោយបំពាន រួមទាំងការផាក ពិន័យ ការព្យួរទោស និង ២ ករណីជាប់ ពន្ធនាគារជាច្រើនឆ្នាំ ។*

**សង្គមស៊ីវិល**



*អង្គការមិនមែនរដ្ឋាភិបាលបានចំណាយអស់ ច្រើនជាង ២៥.០០០ ដុល្លា អាមេរិក ដើម្បីផ្តល់ជំនួយសង្គ្រោះបន្ទាន់ ដល់ប្រពលរដ្ឋ ដែលត្រូវបណ្តេញចេញ ដែលរដ្ឋាភិបាលបានបដិសេធមិនជួយ ។*

**សេរិនអិនជី**



*អចលនៈវត្ថុដ៏មានតម្លៃបំផុតនៅកណ្តាលទីក្រុងភ្នំពេញដែលមានតម្លៃពី ៤៤ លាន ទៅ១៨០ លាន ដុល្លាអាមេរិក*[២៥]

---

[២៥] នៅឆ្នាំ២០០៧ ក្រុមហ៊ុនអចលនៈ វត្ថុ ឈ្មោះ ប៊ុណ្ណា រៀលធី គ្រុប បានរាយការណ៍ថា សហគមន៍ដីក្រហមមានតម្លៃសរុបប្រហែល ៤៤ លានដុល្លាអាមេរិក ។ ការវាយតម្លៃនៅខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០០៨ ដោយ ប៊ុណ្ណា រៀលធី បានកំណត់តម្លៃដីនៅតំបន់ទន្លេបាសាក់ (ដីក្រហម) តម្លៃក្នុង ១ ម៉ែត្រការ៉េ ពី ៣,០០០ ទៅ ៥,០០០ ដុល្លាអាមេរិក ហើយតំបន់ដីក្រហមមានទំហំ ៣.៦ ហិកតា ដែលអាចមានតម្លៃសរុបដល់ទៅ ១៨០ លានដុល្លាអាមេរិក យោងតាមប៉ាន់ស្មាននេះ ។

# សម្បទានដីសេដ្ឋកិច្ច

ខណៈដែលសម្បទានដីសង្គមកិច្ចខុសច្បាប់ បានចេញមុខដើរតួជាមធ្យោបាយមួយដើម្បីរំលោភយកដីដែលមានតម្លៃមានទំហំធំៗនៅកណ្ដាលរាជធានីភ្នំពេញ វិធីដូចគ្នានេះក៏ត្រូវបានកើតឡើងនៅតំបន់ជនបទដែរ តាមរយៈការបង្កើតសម្បទានដីសេដ្ឋកិច្ច ដែលជាការផ្ដល់ដីរដ្ឋឱ្យទៅក្រុមហ៊ុនឯកជននានា ដើម្បីធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម។ រយៈពេលជាច្រើនថ្មីៗកន្លងទៅនេះ ដីជនបទមួយភាគធំត្រូវបានរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមហ៊ុននានា តាមលក្ខណៈសម្បទានដីសេដ្ឋកិច្ច។ រហូតមកទល់ខែធ្នូ ឆ្នាំ២០០៦ គេបានកត់សំគាល់ឃើញមានការអនុវត្តផ្ដល់ដីសម្បទានសេដ្ឋកិច្ចចំនួន ៥៩ កន្លែង ដែលមានផ្ទៃសរុបទំហំ ៩៤៣,០៦៩ ហិកតា នៅក្នុងខេត្ត ចំនួន ១៥ ឬត្រូវជា ៥,២%នៃផ្ទៃដីកម្ពុជាសរុប និងត្រូវជា ១៤,៥% នៃដីដែលអាចដាំដុះបាន។ (ទាំងអស់នេះរួមមាន ដីសម្បទានប្រភេទតូចដែលមានទំហំតូចជាង ១០០ ហិកតា ដែលដីសម្បទានប្រភេទនេះពុំសូវមានព័ត៌មានទេ)[២៦]។ គេនិយាយថា មានតែក្រុមហ៊ុនមួយគត់ដែលគ្រប់គ្រងដី ៧,៤% នៃផ្ទៃដីសរុបទូទាំងប្រទេស។[២៧]

ដូចសម្បទានដីសង្គមកិច្ចដែរ ដីសម្បទានសេដ្ឋកិច្ចភាគច្រើន ច្រើនតែខកខានពុំបានអនុវត្តតាមពាក្យសន្យា **"អភិវឌ្ឍន៍"** ជាមួយសហគមន៍មូលដ្ឋានទេ ហើយក្រុមហ៊ុនមួយចំនួនធំបានអនុវត្តរំលោភលើ ច្បាប់កម្ពុជា។

***ទំហំដីសម្បទានមិនត្រូវលើសពី***

***១០,០០០ ហិកតា***

*មាត្រា ៥៩ ច្បាប់ភូមិបាល (២០០១)*

មិនលើសរយៈពេល ៣ ខែ ក្រោយពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ភូមិបាលឆ្នាំ២០០១ផង រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញសញ្ញាយ៉ាងច្បាស់អំពីគោលបំណងក្នុងការអភិវឌ្ឍជនបទ ដោយការផ្ដល់ដីសម្បទានទំហំ ១០០,៨៥២ ហិកតា នៅខេត្តស្ទឹងត្រែង ឱ្យក្រុមហ៊ុន ម៉ុង

---

[២៦] ទស្សនៈសិទ្ធិមនុស្ស: *សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧ មាននៅក្នុងគេហទំព័រ: http://cambodia.ohchr.org/EN/report_thematic.htm

[២៧] ក្រុមហ៊ុន ភាពីម៉ិច ដែលជាក្រុមហ៊ុនរបស់អ្នកស្រី ជឹង សុភាព និងប្ដីរបស់គាត់ ដែលជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា ឈ្មោះ ឡៅ ម៉េងឃីន: *ខ្សែស្រឡាយអ្នកលក់ជាតិ: ការកាប់ឈើខុសច្បាប់ និងពុះច្រៀកទ្រព្យសម្បត្តិសាធារណៈ ដោយអ្នកដឹកនាំរបស់ប្រទេសកម្ពុជា* របាយការណ៍ គ្លូបប៊ល វិតណេស ខែមិថុនា ឆ្នាំ២០០៧។ http://globalwitness.org

រីទ្ធិ គ្រុប[២៨]។ ហើយនេះពុំមែនជា ដីសម្បទានខុសច្បាប់ចុងក្រោយដែលត្រូវផ្តល់ឱ្យក្រុមហ៊ុននោះទេ។

- នៅខែកញ្ញា ឆ្នាំ២០០៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាពជាគោលការណ៍ ផ្តល់ដីសម្បទានសេដ្ឋកិច្ច ឱ្យក្រុមហ៊ុនចំនួនពីរ ដែលមានទំហំ ១៩,៩០០ ហិកតា នៅខេត្តមណ្ឌលគីរី។[២៩]
- នៅខែមេសា ឆ្នាំ២០០៨ ក្រុមហ៊ុន កូរ៉េ មួយឈ្មោះ Kenertec បានទទួលដីសម្បទានសេដ្ឋកិច្ចទំហំ ៦០,០០០ ហិកតា ដែលផ្តល់ឱ្យដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដើម្បីដាំដើមឈើ និងសាងសង់រោងចក្រអគ្គិសនី ដើរដោយជីវចម្រុះ[៣០]។

ក្រៅពី សម្បទានដីសេដ្ឋកិច្ចខុសច្បាប់ទាំងនោះ នៅមានសម្បទានដីធំៗចំនួន ៨ កន្លែងទៀតដែលមានទំហំលើសពី ១០,០០០ ហិកតា មានចែងរួចហើយ នៅពេលដែលច្បាប់ភូមិបាលត្រូវបានអនុម័ត។ នៅឆ្នាំ ២០០៥ អនុក្រិត្យស្តីពី សម្បទានដីសេដ្ឋកិច្ច បានដាក់ចេញនូវនីតិវិធីនានា ដែលតម្រូវឱ្យមានការត្រួតពិនិត្យ ឡើងវិញចំពោះដីសម្បទានប្រភេទនេះ និងកាត់បន្ថយមកនៅត្រឹមទំហំដែលច្បាប់បានកំណត់វិញ។ ប៉ុន្តែ ៣ ឆ្នាំក្រោយមក យោងតាមរបាយការណ៍របស់វេទិកានៃអង្គការមិនមែនរាជរដ្ឋាភិបាល បានរកឃើញថា មានតែដីសម្បទានរបស់ក្រុមហ៊ុនចំនួនពីរប៉ុណ្ណោះ ដែលត្រូវបានកាត់បន្ថយទំហំ ហើយម្ចាស់ ៣ នាក់ របស់សម្បទានដីសេដ្ឋកិច្ចដែលមានទំហំលើសច្បាប់កំណត់នោះ (រួមទាំងលោកឧកញ៉ា ម៉ុង រីទ្ធិ) បានបដិសេធមិនព្រមចរចារកិច្ចព្រមព្រៀងសារជាថ្មីឡើយ[៣១]។

---

[២៨] ស្ថានភាពទូទៅនៃដីសម្បទានសេដ្ឋកិច្ច ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មាននៅក្នុងគេហទំព័រ: http://www.elc.maff.gov.kh/comprofiles/stgsea/html និងទស្សនៈសិទ្ធិមនុស្ស: *សម្បទានដីនៅកម្ពុជា* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧ មាននៅក្នុងគេហទំព័រ: http://cambodia.ohchr.org/EN/report_thematic.htm

[២៩] ក្រុមការងារបច្ចេកទេសស្តីពីបរិស្ថាន និងរុក្ខាប្រមាញ់-បញ្ជីក្រុមហ៊ុន ដីសម្បទានសេដ្ឋកិច្ច ដែលបានចុះហត្ថលេខាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ : www.twgfe.org/Docs/Statistics/Land%20Concession.pdf និងទស្សនៈសិទ្ធិមនុស្ស: *ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧។

[៣០] សេចក្តីប្រកាសព័ត៌មានរបស់ក្រុមហ៊ុន: *ក្រុមហ៊ុនKenertic កសាងរោងចក្រអគ្គិសនីប្រើជីវចម្រុះនៅកម្ពុជា* ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៧។ មាននៅក្នុងគេហទំព័រ: http://www.kenertic.co.kr/english/relations/whatsnew_read..asp?page=2&num=12

[៣១] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា: *របាយការណ៍តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍនៅកម្ពុជា ក្នុងឆ្នាំ២០០៧-២០០៨* ខែវិច្ឆិកា ឆ្នាំ២០០៨។

ការអនុវត្តន៍ជាទូទៅមួយទៀតគឺ បង្កើតសម្បទានដីសេដ្ឋកិច្ចដោយការផ្ដុំសម្បទានដីសេដ្ឋកិច្ចតូចៗ ចំនួនពីរ ឬ ច្រើនកន្លែងជាប់ៗគ្នា។ ឧទាហរណ៍ នៅថ្ងៃដដែលនោះក្នុងឆ្នាំ២០០៦ ក្រុមហ៊ុនពីរមានទីស្នាក់ការនៅជាមួយគ្នាក្នុងរាជធានីភ្នំពេញ បានទទួលដីសម្បទាននៅជិតគ្នាបង្កើយក្នុងខេត្តកោះកុង ដើម្បីធ្វើចម្ការអំពៅ។ ក្រុមហ៊ុននិមួយៗបានទទួលដីសម្បទានទំហំតូចជាង ១០,០០០ ហិកតា ប៉ុន្តែទំហំដីសរុបរបស់ក្រុមហ៊ុនទាំងពីរនេះគឺ ១៩,១០០ ហិកតា[៣២]។ យោងតាមរបាយការណ៍ឆ្នាំ២០០៧ របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ បានរកឃើញនូវព័ត៌មានដែលអាចជឿជាក់ថា ឯកឧត្តម លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជា ជាម្ចាស់ក្រុមហ៊ុនទាំងពីរនោះ។

ការអនុវត្តន៍បែបនេះ មិនបានកេងយកចំណេញពីភាពខ្វះចន្លោះនៅក្នុងច្បាប់ភូមិបាលទេ ប៉ុន្តែរំលោភច្បាប់នេះតែម្តង។ តាមពិត ដីសម្បទាននេះមានទំហំសរុបលើសពី ១០,០០០ ហិកតា ហើយដែលត្រូវផ្ដល់ឱ្យមនុស្សតែម្នាក់ប៉ុណ្ណោះ ឬ ក្រុមហ៊ុនផ្សេងគ្នា ដែលគ្រប់គ្រងដោយមនុស្សតែម្នាក់ វាជាការខុសច្បាប់ ទោះបី ជាស្ថិតនៅលើទីតាំងខុសគ្នាក៏ដោយ[៣៣]។ នៅក្នុងបញ្ហានេះ អ្នកដែលរំលោភច្បាប់ភូមិបាលខ្លាំងជាងគេគឺ ឯកឧត្តម ឡៅ ម៉េងឃីន សមាជិក ព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជា ដែលគេបានដឹងថា ក្រៅពីសម្បទានដីសេដ្ឋកិច្ចមានទំហំ ៣១៥,០២៥ហិកតា នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យក្រុមហ៊ុនលោកឈ្មោះ ភាពីម៉ិច (កិច្ចសន្យាមុនឆ្នាំ២០០១ ដែលក្រុមហ៊ុនភាពីម៉ិចបានបដិសេធមិនព្រមចរចារឡើងវិញ)។ លោកបានប្រើប្រាស់ក្រុមហ៊ុនមួយទៀត ដែលលោក គឺជានាយកក្រុមហ៊ុននោះដែរ ដើម្បីទទួលបានដីសម្បទានបន្ថែម ១៩៩,៩៩៩ ហិកតា ទៀត នៅខេត្តមណ្ឌលគីរី (ផ្ដល់ជាគោលការណ៍ឱ្យទៅក្រុមហ៊ុនឈ្មោះ វូស៊្រីសាន) ព្រមទាំងដីទំហំ ១៣៣ ហិកតា ទៀត នៅតំបន់អភិវឌ្ឍន៍បឹង កក់ ក្នុងរាជធានីភ្នំពេញ (ក្រុមហ៊ុនឈ្មោះ ស៊ូកាគូ)[៣៤]។

---

[៣២] ឯកសារសម្បទានដីសេដ្ឋកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មាននៅក្នុងគេហទំព័រ: http://www.elc.maff.gov.kh/comprofiles/stgsea/html និង http://www.elc.maff.gov.kh/comprofiles/kksugar.html

[៣៣] ច្បាប់ភូមិបាល (ឆ្នាំ២០០១) មាត្រា ៥៩ កថាខណ្ឌ ៣។

[៣៤] ជាដំបូងដីសម្បទានទំហំ ១០,០០០ ហិកតា ត្រូវបានធ្វើសម្បទានឱ្យក្រុមហ៊ុន វូស៊្រីសាន នៅឆ្នាំ២០០៤ ប៉ុន្តែ ក្រុមហ៊ុននេះបានរំលោភយកដីលើសពីទំហំដែលបានកំណត់នេះទៅទៀត។ សូមអានរបាយការណ៍: ទស្សនៈសិទ្ធិមនុស្ស: *ដីសម្បទានដើម្បីគោលបំណងសេដ្ឋកិច្ចនៅកម្ពុជា:* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០៤ និងទស្សនៈសិទ្ធិមនុស្ស: *សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា:* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧ មាននៅក្នុងគេហទំព័រ: http://cambodia.ohchr.org/EN/report_thematic.htm

បន្ថែមលើការរំលោភច្បាប់ភូមិបាលពាក់ព័ន្ធយ៉ាងច្បាស់ក្រឡែត អំពីទំហំដីសម្បទានសេដ្ឋកិច្ចនេះ រាជរដ្ឋាភិបាល នៅតែមិនអាចអនុវត្តតាមបញ្ញត្តិកំណត់នៅក្នុងច្បាប់ អំពីបញ្ហាតម្លាភាពក្នុងការផ្តល់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច តាមរយៈការបង្ហាញកិច្ចសន្យាទាំងអស់នោះនៅក្នុងបញ្ជីណាមួយ ដែលអាចដឹងបានជាសាធារណៈ។ ដោយទិន្នន័យស្តីពីសម្បទានដីសេដ្ឋកិច្ច មានតិចតួចបំផុតនៅក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នោះជាព័ត៌មានមិនពេញលេញ មិនសុក្រិត្យ និងអាចជាព័ត៌មានផ្ទុយថែមទៀត។ ដូចដែលអ្នកវិភាគនៃសង្គមស៊ីវិលបានសង្កេតឃើញនោះថា ប្រភពអ៊ីនធឺណេតជាភាសាអង់គ្លេសនោះ គឺជាមធ្យោបាយទទួលព័ត៌មានដ៏ពិបាកជាទីបំផុតមួយ សម្រាប់ប្រជាពលរដ្ឋនៅសហគមន៍នានា ក្នុងប្រទេសកម្ពុជា[៣៥]។

នៅក្នុងការជឿជាក់របស់ខ្លួន សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ បានធ្វើការកត់សំគាល់អំពីបញ្ហានានាពាក់ព័ន្ធសម្បទានដីសេដ្ឋកិច្ចទាំងឡាយហើយបានដាក់ចេញនូវគំរូជាក់លាក់មួយ នៅក្នុងសូចនាករត្រួតពិនិត្យរួមគ្នាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីឱ្យរាជរដ្ឋាភិបាលធ្វើការកែលំអអំពីបញ្ហានេះ។ ជាការអាម៉ាស់របស់ខ្លួន សហគមន៍អ្នកផ្តល់ជំនួយនេះ បានបន្តបង្កើនជំនួយថែមទៀត ទោះបីជារដ្ឋាភិបាល បានធ្វើព្រងើយកន្តើយអំពីសូចនាករត្រួតពិនិត្យរួមគ្នានេះក៏ដោយ ជាពិសេសអំពីបញ្ហាតម្លាភាពដែលតម្រូវឱ្យមាន និងសូចនាករ មួយដើម្បីធ្វើការត្រួតពិនិត្យឡើងវិញអំពីទំហំសម្បទានដីសេដ្ឋកិច្ចទាំងឡាយ ក្រោយពីរដ្ឋាភិបាលខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងនោះ ហើយបំភ្លេចចោលដោយស្ងាត់ៗ។

---

[៣៥] McInnes ព្រឹត្តិប័ត្រសារព័ត៌មាន ចលនាព្រៃពិភពលោកលេខ១៣៧ ខែធ្នូ ឆ្នាំ២០០៨ *ចេតនាក្នុងការតាក់តែងបទបញ្ញត្តិស្តីពីចម្ការកសិ-ឧស្សាហកម្មនៅកម្ពុជា*។ មាននៅក្នុងគេហទំព័រ http://www.wrm.org.uy/bulletin/137/cambodia_2.html

| កិច្ចប្រជុំរបស់សហគមន៍ផ្តល់ជំនួយ | សូចនាករត្រួតពិនិត្យរួម សម្បទានដីសេដ្ឋកិច្ច |
|---|---|
| ខែមីនា ឆ្នាំ២០០៦ កិច្ចប្រជុំពីគ្រោះយោបល់លើទី ៨ (សន្យាផ្តល់ជំនួយ ៦០១ លានដុល្លាអាមេរិក) | បង្កើតយន្តការ និងផ្សព្វផ្សាយព័ត៌មានតាមដំណាក់កាលស្តីពីសម្បទានដីសេដ្ឋកិច្ចតាមសេចក្តីជូនដំណឹងរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ ។ |
| ខែមិថុនា ឆ្នាំ២០០៧ វេទិកាស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ១ (សន្យាផ្តល់ជំនួយ ៦៨៩ លានដុល្លាអាមេរិក) | អនុវត្តគ្រប់បញ្ញត្តិទាំងអស់នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចព្រមទាំងបង្កើត និងបោះពុម្ពសៀវភៅបញ្ជីកត់ត្រាសម្បទានដីសេដ្ឋកិច្ច រួមទាំងដីសម្បទានដែលផ្តល់ដោយអាជ្ញាធរខេត្តផង និងពិនិត្យឡើងវិញ យ៉ាងតិចសម្បទានដីសេដ្ឋកិច្ចចំនួន៥ ដែលមានទំហំលើសពី ១០,០០០ ហិកតា ចាត់វិធានការសមរម្យតាមជំពូក៦ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ។ |
| ខែធ្នូ ឆ្នាំ២០០៨ វេទិកាស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ (សន្យាផ្តល់ជំនួយ ៩៥២ លានដុល្លាអាមេរិក)[៣៦] | អនុវត្តគ្រប់បញ្ញត្តិទាំងអស់នៅក្នុងច្បាប់ និងបទបញ្ញត្តិ រួមទាំងការបង្កើត និងបោះពុម្ពសៀវភៅបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានដីរ៉ែ និងទម្រង់សម្បទានផ្សេងៗទៀត ដែលស្ថិតក្រោមយុត្តាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ |

ដូចក្នុងបញ្ហាសម្បទានដីសង្គមកិច្ចដែរ មើលទៅហាក់ដូចជាមានភស្តុតាងតិចតួចណាស់ ដែលសម្បទានដីសេដ្ឋកិច្ច បានធ្វើការអភិវឌ្ឍជាវិជ្ជមានសម្រាប់ប្រជាពលរដ្ឋកម្ពុជាសាមញ្ញ ដែលមិនមានជោគវាសនា រស់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចទាំងនេះ។ ការវាយតម្លៃរបស់លោកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានរៀបរាប់អំពីផលប៉ះពាល់នានាដែលបណ្តាលមកពីការធ្វើសម្បទានដីទៅលើសហគមន៍មូលដ្ឋាន ដោយរួមបញ្ចូលទាំងការរំលោភលើដីធ្លី និងការប៉ះពាល់ផលប្រយោជន៍ ជីវភាពជាប្រពៃណី ការបាត់បង់លំនៅឋាន ការប៉ះពាល់បរិស្ថាន ការផ្តល់ការងារតិចតួច និងលក្ខខណ្ឌការងារមិនសមរម្យ អំពើហិង្សា និងការបំភិតបំភ័យ ព្រមទាំងកង្វះការដោះស្រាយឱ្យមាន

[៣៦] មិនបូកបញ្ចូលតួលេខរបស់ប្រទេសខ្លះ ដូចជា អាមេរិក និងបែលហ្សិក ដែលមិនទាន់បានកំណត់ចំនួននៃជំនួយនេះច្បាស់លាស់នៅឡើយ ដូច្នេះជំនួយសរុបដែលសង្ឃឹមទុកអាចដល់ ១ កោដិដុល្លាអាមេរិក។

ប្រសិទ្ធិភាព សងការខូចខាតឱ្យបានសមរម្យ ឬ ជួយជ្រោមជ្រែងដល់សហគមន៍ដែលរងផលប៉ះពាល់ទាំងនោះ[៣៧]។

ស្រដៀងគ្នានេះដែរ តាមការសិក្សាជាក់លាក់មួយ ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល នៅលើសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចម្ការកៅស៊ូជប់ នៅទឹរីង ខេត្តកំពង់ធំ ដែលមានទំហំ ៦,១០០ ហិកតា បានរកឃើញថា ជាលទ្ធផលនៃការផ្តល់ដីសម្បទាន ប្រជាពលរដ្ឋនៅមូលដ្ឋានមិនអាចចូលទៅក្នុងព្រៃដើម្បីរកអនុផលព្រៃឈើសំខាន់ៗមួយចំនួន ដូចមុនទៀតឡើយ ប្រជាពលរដ្ឋទាំងនោះត្រូវលក់គោ ក្របី ដោយសារតែការផាកពិន័យពេលគោ ក្របី ដើរចូលក្នុងដីរបស់ក្រុមហ៊ុន និងថែមទាំងគ្មានដីដើម្បីធ្វើស្រែចម្ការចិញ្ចឹមគ្រួសារទៀតផង។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា បានធ្វើការសន្និដ្ឋានថា ដោយសារការធ្វើសម្បទាននោះ "ប្រជាពលរដ្ឋកាន់តែជួបប្រទះភាពក្រីក្រខ្លាំងឡើង"[៣៨]។ ហើយដូចដែលករណីកំពុងកើតឡើងជាបន្តនៅខេត្តក្រចេះ នោះបង្ហាញថា ប្រជាពលរដ្ឋមូលដ្ឋាននឹងត្រូវបានចូលធ្វើកាងារនៅក្នុងក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ច នោះជាការមិនត្រឹមត្រូវទេ។

---

[៣៧] ទស្សនះសិទ្ធិមនុស្ស: *សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា:* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧។

[៣៨] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា: *ការសិក្សាអំពីផលប៉ះពាល់ដោយការអភិវឌ្ឍចម្ការកៅស៊ូនៅទឹរីង ខេត្តកំពង់ធំ ប្រទេសកម្ពុជា* ខែឧសភា ឆ្នាំ២០០៥។ មាននៅក្នុងគេហទំព័រ: http://www.ngoforum.org.kh/Docs/Forestry/IRP/irp.htm

## ករណីសិក្សា : ក្រុមហ៊ុន ស៊ី អាយ វី នៅខេត្តក្រចេះ



នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ដីសម្បទានសេដ្ឋកិច្ចមួយកន្លែងត្រូវបានផ្តល់ឱ្យក្រុមហ៊ុនកម្ពុជាមួយឈ្មោះ ស៊ី អាយ វី សម្រាប់ធ្វើចម្ការកៅស៊ូ នៅស្រុកស្នួល ខេត្តក្រចេះ។ សម្បទានដីសេដ្ឋកិច្ចនោះមានទំហំ ៧៦៩ ហិកតា ជាដីសម្បទានមួយកន្លែងក្នុងចំណោម ៣៥ កន្លែង ដែលត្រូវបានផ្តល់ឱ្យទៅក្រុមហ៊ុនក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ហើយដីនោះគឺជាដីរបស់សហគមន៏ជនជាតិស្មៀងរាប់រយគ្រួសារ កាន់កាប់រួមគ្នា តាំងពីសម័យដូនតាមកម្ល៉េះ។ ទោះបីជា ច្បាប់ភូមិបាលឆ្នាំ២០០១ បានហាមឃាត់មិនឱ្យមានការលក់ទិញដីជនជាតិភាគតិចក៏ដោយ។ គ្រួសារដែលបានរងគ្រោះនិយាយថា ពួកគាត់មិនត្រូវបានក្រុមហ៊ុនមកពិភាក្សា អំពីផែនការណាមួយឡើយ ដែលទង្វើបែបនេះជាការផ្ទុយទៅនឹងអនុក្រិត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

ក្រោយពីក្រុមហ៊ុន បានបញ្ជូនគ្រឿងចក្រទៅឈូសឆាយដីស្រែ និងចម្ការដំឡូងមីរបស់ប្រជាពលរដ្ឋ ពួកគាត់បានសម្រេចចិត្តនូវវិធានការរួមគ្នាមួយ។ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៨ ប្រជាពលរដ្ឋ ៣០០ នាក់ បានធ្វើការតវ៉ាដោយសន្តិវិធីលើទីតាំង ដីទំនាស់ដើម្បីទាមទារឱ្យកម្មករក្រុមហ៊ុនរុះរើជុំរំ ដែលគេបានសាងសង់នោះចេញពីដី។ ពីរសប្តាហ៍ក្រោយមក សមាជិកសហគមន៏ចំនួន៤នាក់ត្រូវបានកោះហៅដោយតុលាការខេត្តក្រចេះដើម្បីសាកសួរ ក្រោមការចោទប្រកាន់ពីបទប្លន់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពាក់ព័ន្ធនឹងការ



តវ៉ានោះ (ទោះបីជាគ្មានអំពើហិង្សាណាមួយកើតឡើងនៅក្នុងការតវ៉ានោះក៏ដោយ។ គ្មានភស្តុតាងណាមួយ ត្រូវបានបង្ហាញដើម្បីចោទប្រកាន់បុរសទាំង ៤ នាក់ នោះឡើយ ក្រៅតែពីពាក្យបណ្តឹងរបស់ក្រុមហ៊ុន ស៊ី អាយ វី ប៉ុណ្ណោះ ហើយបុរសម្នាក់ ក្នុងចំណោមបុរសទាំងនោះ មិនបានចូលរួមក្នុងការតវ៉ានោះទេ។ ករណីនេះនៅតែបន្តស៊ើបអង្កេតដោយតុលាការនៅឡើយ។

លើសពីការប្រើប្រាស់យ៉ាងស្ទាត់ជំនាញ នូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌមិនត្រឹមត្រូវ ដើម្បីបំភិត

បំភ័យនូវសមាជិកសហគមន៍ណាដែលធ្វើការតវ៉ា និងជនរងគ្រោះផ្សេងទៀត ដើម្បីឱ្យពួកគាត់បញ្ឈប់ការតវ៉ា ករណីនោះក៏បានបញ្ជាក់ឱ្យឃើញថាគម្រោង **"អភិវឌ្ឍន៍"** នេះអាចនាំមកនូវផលចំណេញជាវិជ្ជមានដល់សហគមន៍មូលដ្ឋាន។ នាយកគ្រប់គ្រងក្រុមហ៊ុន ស៊ី អាយ វី គ្រុប ដែលជាក្រុមហ៊ុនមេ បានបញ្ជាក់ថា ក្រុមហ៊ុនចង់ឱ្យប្រជាពលរដ្ឋនៅក្នុងសហគមន៍ធ្វើការនៅក្នុងចម្ការកៅស៊ូ ប៉ុន្តែតាមការសម្ភាសន៍ប្រជាពលរដ្ឋនៅក្នុងរឿងនេះថា ពួកគេគ្មានចំណាប់អារម្មណ៍ក្នុងការស៊ីឈ្នួលធ្វើជាកម្មករនោះទេ គេចង់ធ្វើការសម្រាប់ខ្លួនឯងតែប៉ុណ្ណោះ។ ដូច្នេះ បើមានការពិគ្រោះយោបល់ពីមុនមកជាមួយប្រជាពលរដ្ឋ នៅពេលនោះក្រុមហ៊ុន ស៊ី អាយ វី អាចដឹងអំពីបញ្ហានេះ។ ជាការពិតណាស់ អាជ្ញាធរមូលដ្ឋានប្រាកដជាបានដឹងច្បាស់អំពីបញ្ហានេះ ដូចដែលលោកលេខាធិការរងខុទ្ទកាល័យសាលាខេត្តក្រចេះ បានប្រាប់អ្នកស្រាវជ្រាវថា "យើងចង់ឱ្យពួកគេ (ជនជាតិភាគតិច) ធ្វើការឱ្យក្រុមហ៊ុននៅក្នុងតំបន់របស់ខ្លួន ប៉ុន្តែប្រជាពលរដ្ឋមានទម្លាប់មិនចង់ធ្វើជាកម្មករ។ ដូច្នេះ កម្មកររបស់ក្រុមហ៊ុនសុទ្ធតែមកពីស្រុកផ្សេងៗ។"[៣៩]

□□□

[៣៩] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ឆ្នាំ២០០៨ និងករណីសិក្សាមិនផ្សព្វផ្សាយរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ខែមករា ឆ្នាំ២០០៩។

# ការពាក់ព័ន្ធរបស់យោធានៅក្នុងការរំលោភយកដី និងការបណ្តេញដោយបង្ខំ

ទិដ្ឋភាពមួយដែលរំខាន និងគ្រោះថ្នាក់បំផុតនៃការរំលោភយកដីធ្លីរាលដាលពាសពេញនៅកម្ពុជា គឺការពាក់ព័ន្ធទៅនឹងយោធា ជាពិសេសនៅតាមតំបន់ជនបទ។ នៅក្នុងឆ្នាំ២០០៨ លីកាដូ ទទួលបានចំនួន ២៧ ករណី នៅក្នុងខេត្តគោលដៅរបស់ខ្លួន ដែលសមាជិកនៃកងយោធពលខេមរភូមិន្ទ មានការពាក់ព័ន្ធក្នុងការរំលោភទាក់ទងនឹងបញ្ហាដីធ្លីមកលើប្រជាពលរដ្ឋស៊ីវិល (សូមមើលតារាងខាងក្រោម)។



*កងរាជអាវុធហត្ថ យាមភូមគ្រឹះ របស់សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា ឡៅ ម៉េងឃីន។ ការិយាល័យក្រុមហ៊ុនភាពីម៉ិច ដៃគូក្រុមហ៊ុន* WuZinShan *និងស៊ូកាគូ*

ការពាក់ព័ន្ធរវាងសមាជិកនៃកងយោធពលខេមរភូមិន្ទ និងការរំលោភយកដី គឺជាបញ្ហាកើតមានតាំងពីយូរយារមកហើយ។

ការស៊ើបអង្កេតជាច្រើនបានកត់សំគាល់ឃើញនូវតួនាទីរបស់យោធា ក្នុងការយាមកាមដីសម្បទាន និងផលប្រយោជន៍ផ្សេងៗរបស់ពាណិជ្ជករមានអំណាចធំៗ ព្រមទាំងការធ្វើប្រតិបត្តិការនៅតាមមូលដ្ឋាន ដោយកងយោធាផ្ទាល់តែម្តង ដូចជាការកាប់ឈើខុសច្បាប់ជាដើម[៤០]។ ពួកយោធាទាំងនោះក៏មានការពាក់ព័ន្ធក្នុងការរំលោភយកដីធ្លីយ៉ាងធ្ងន់ធ្ងរ ជួនកាលរំលោភយកខ្លួនឯង ហើយពេលខ្លះទៀតរំលោភក្នុងនាមមន្ត្រីរាជរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងអ្នកមានអំណាចធំៗមួយចំនួនទៀត។ ជាច្រើនលើកច្រើនសារ កងយោធាប្រដាប់អាវុធ បានចូលរួមសហការនៅក្នុងការបណ្តេញ

[៤០] សូមមើលឧទាហរណ៍ របាយការណ៍របស់អង្គការក្លូបបិល វិតណេស *ការកាប់បំផ្លាញព្រៃឈើ គ្មានដែនកំណត់ (ឆ្នាំ២០០២) ខ្សែស្រឡាយអ្នកលួចជាតិ (ឆ្នាំ២០០៧) និងប្រទេសជាតិលក់ (ឆ្នាំ២០០៩)* មាននៅក្នុងគេហទំព័រ : http://www.globalwitness.org

ប្រជាពលរដ្ឋចេញពីលំនៅឋាន ក្រោមបញ្ជារបស់មន្ត្រីរាជរដ្ឋាភិបាល ដែលជាធម្មតាបណ្តាលឱ្យមានការចាប់ខ្លួន របួស និងមានការស្លាប់ជនស៊ីវិល។

ឧទាហរណ៍ នៅខែមេសា ឆ្នាំ២០០៧ មន្ត្រីយោធពលខេមរភូមិន្ទ គឺជាកម្លាំងមួយក្រុមដែលបណ្តេញប្រជាពលរដ្ឋចំនួន ១០៥ គ្រួសារ ចេញពីលំនៅឋានដោយបង្ខំ នៅភូមិស្ពានឆេះ ក្រុងព្រះសីហនុ បណ្តាលឱ្យរបួស ១៨ នាក់ និងចាប់ខ្លួនមនុស្ស ១៣ នាក់ (ហើយនេះ គឺជាករណីមួយទៀតដែលជាច្រើនឆ្នាំក្រោយពីការបណ្តេញប្រជាពលរដ្ឋមក នៅតែមិនទាន់មានការអភិវឌ្ឍនៅឡើយ)។ ក្រោយមកក្នុងឆ្នាំ ដដែលនោះ យោធា និងនគរបាលប្រដាប់ដោយអាវុធធន់ធ្ងន់ជាច្រើនត្រូវបានដាក់ ពង្រាយនៅក្នុងព្រឹត្តិការណ៍បណ្តេញប្រជាពលរដ្ឋចំនួន ៣១៧ គ្រួសារ នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលក្នុងពេលនោះជនស៊ីវិលពីរនាក់គ្មានអាវុធត្រូវបានបាញ់សម្លាប់ រួមទាំងម្តាយម្នាក់ផង ដែលត្រូវបាញ់នៅកណ្តាលវាល នៅចំពោះមុខកូន ៤ នាក់ ហើយ ៦ នាក់ផ្សេងទៀតបានរងរបួស។ ក្រោយពីមានការបណ្តេញដោយបង្ខំ កងយោធា និងនគរបាលទាំងនោះ បានលួចយកទ្រព្យសម្បត្តិរបស់គ្រួសារដែលត្រូវបានបណ្តេញចេញនោះ ព្រមទាំងរារាំងអ្នកឃ្លាំមើលសិទ្ធិមនុស្សមិនឱ្យចូលក្នុងតំបន់នោះថែមទៀតផង។



*យោធាដែលបានចូលរួមក្នុងការបណ្តេញចេញ បណ្តាលឱ្យប្រជាពលរដ្ឋស្លាប់ កាលពីខែវិច្ឆិកា ឆ្នាំ២០០០ នៅខេត្តព្រះវិហារ។ នៅពីក្រោយពួកគេ គឺជារថយន្តដឹកកង់ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ*

យោងតាមច្បាប់ភូមិបាល និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងច្បាប់យោធាកម្ពុជា យោធាពុំមានអំណាចក្នុងការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋានឡើយ។ យោធាមានតួនាទីមិនដូច នគរបាល និងកងរាជអាវុធហត្ថទេ គឺយោធាពុំអាចអនុវត្តសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ដូចជាដីការបញ្ជារបស់តុលាការក្នុងការរុះរើលំនៅឋានជាដើម។ (តាមពិតការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋានភាគច្រើន គឺជាការអនុវត្តន៍ខុសច្បាប់ ទោះបីជាអាជ្ញាធរណាអនុវត្តក៏ដោយ ក៏សុទ្ធតែខុសច្បាប់ទាំងអស់ ពីព្រោះការអនុវត្តន៍ទាំងនោះ គឺពុំមានបញ្ជាពីតុលាការ និងពុំមានដំណើរការសមស្របក្នុងការអនុវត្តន៍ទៅលើគ្រួសាររងគ្រោះឡើយ)។ ហើយវាក៏ជាគោលការណ៍គ្រឹះ របស់ច្បាប់អន្តរជាតិផងដែរ ដែលចែងថា យោធាមិនត្រូវយកមក

ប្រើជាមួយនឹងប្រជាពលរដ្ឋដែលគ្មានអាវុធទេ។ ករណីទាំងឡាយដែល លីកាដូ បានកត់ត្រាទុកជាឯកសារ បានបង្ហាញឱ្យឃើញថា គោលការណ៍នេះ នៅតែមិនទាន់បានអនុវត្ត ហើយនិទ្ទណ្ឌភាពនៅតែមានដដែល ។

## ការពាក់ព័ន្ធរបស់យោធាកងយោធពលខេមរភូមិន្ទ ក្នុងការរំលោភលើប្រជាពលរដ្ឋ ទាក់ទងនឹងបញ្ហាដីធ្លី ដែលអង្គការលីកាដូបានស៊ើបអង្កេត ក្នុងឆ្នាំ២០០៨ ពីខែមករា ឆ្នាំ២០០៨ ដល់ ខែមករា ឆ្នាំ២០០៩




| DAP | FE | IAD | LG | PA |
|---|---|---|---|---|
| ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ | ការបណ្តេញចេញដោយបង្ខំ | ការចាប់ និង ឃុំខ្លួនខុសច្បាប់ | ការរំលោភយកដីធ្លី | ការបង្ករបួសស្នាម |

| | កាលបរិច្ឆេទ ព្រឹត្តិការណ៍សំខាន់ៗ | ព្រឹត្តិការណ៍ដែលបានកើតឡើង |
|---|---|---|
| IAD FE | ថ្ងៃទី០១ ខែមករា | បុរសម្នាក់អាយុ ៥៥ ឆ្នាំ ត្រូវបានចាប់ខ្លួនដោយខុសច្បាប់ ដោយកងយោធពលខេមរភូមិន្ទខេត្ត ក្នុងការប៉ុនប៉ងដើម្បីបណ្តេញគ្រួសារគាត់ចេញពីដីរបស់ខ្លួន នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ |
| LG | ឯថ្ងៃទី០១ ខែកុម្ភៈ | ភូមិមួយមានប្រជាពលរដ្ឋចំនួន ១,៣៦២ គ្រួសារ ប្រឈមមុខនឹងការបណ្តេញដោយបង្ខំ ហើយត្រូវបានហ៊ុំព័ទ្ធដោយកំលាំងចម្រុះរួមមាន យោធា នគរបាល និងកងរាជអាវុធហត្ថ នៅស្រុកសន្ទុក ខេត្តកំពង់ធំ ។ ដីទំនាស់នោះ គឺត្រូវបានរាជរដ្ឋាភិបាលកម្ពុជាជួលឱ្យក្រុមហ៊ុនឯកជនមួយ របស់វៀតណាមឈ្មោះ ទិន បៀន ជាសម្បទានដីសេដ្ឋកិច្ច ។ |
| DAP LG | ថ្ងៃទី០៧ ខែមីនា | មេបញ្ជាការអង្គភាពអភិវឌ្ឍន៍ទី ៤ នៃយោធភូមិភាគ ៥ និងមេបញ្ជាការរង បានប៉ុនប៉ងរំលោភយកដីពីប្រជាពលរដ្ឋចំនួន ១៥៧ គ្រួសារ ។ កងយោធពលខេមរភូមិន្ទ បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋដោយខុសច្បាប់នៅលើដីទំនាស់នោះ ហើយបានបាញ់រះទៅលើសហគមន៍ និងធ្វើការគំរាមកំហែងដល់អាយុជីវិតប្រជាពលរដ្ឋនៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។ |
| PA | ថ្ងៃទី០៨ ខែមីនា | យោធានៃកងយោធពលខេមរភូមិន្ទម្នាក់ ប្រចាំការនៅស្រុកម៉ាឡៃ បានបាញ់ និងធ្វើឱ្យរបួសប្រជាពលរដ្ឋចំនួន ៣ នាក់ នៅក្នុងទំនាស់ដីធ្លីមួយ ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៤៥០ នាក់ នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ |

| | | |
|---|---|---|
| LG | ថ្ងៃទី០៨ ខែមីនា | ប្រជាពលរដ្ឋចំនួន ៨៤ គ្រួសារ នៅក្នុងទំនាស់ដីធ្លីមួយ ជាមួយនាយកសមាគមសង្គ្រោះជនពិការ ត្រូវបានគំរាមកំហែង ហើយម្នាក់ត្រូវបានវាយដំដោយកងកម្លាំងចម្រុះដែលមានយោធា និងនគរបាល នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ |
| LG | ថ្ងៃទី២០ ខែមីនា | ដីមួយកន្លែងដែលជារបស់ប្រជាពលរដ្ឋ ១៥២ គ្រួសារ ត្រូវបានអាជ្ញាធរមូលដ្ឋានរំលោភយកដោយខុសច្បាប់ ។ យោធាកងពលតូចលេខ ៣១ បានធ្វើការគំរាមកំហែងទៅលើប្រជាពលរដ្ឋទាំងនោះនៅស្រុកឈូក ខេត្តកំពត ។ |
| LG | ថ្ងៃទី០៤ ខែមេសា | ដីស្រែជារបស់ប្រជាពលរដ្ឋ ២៥ គ្រួសារ ត្រូវបានក្រុមហ៊ុន ខេន រំលោភយក ។ យោធានៃកងយោធពលខេមរភូមិន្ទម្នាក់ដែលយាមដីនោះគំរាមកំហែង បុរសតំណាងសហគមន៍ម្នាក់ អាយុ ៥៨ ឆ្នាំ នៅស្រុកសូត្រនិគម ខេត្តសៀមរាប ។ |
| PA<br>LG | ថ្ងៃទី០៥ ខែមេសា | ដីមួយកន្លែងដែលដំបូងត្រូវបានអាជ្ញាធរមូលដ្ឋានសន្យាឱ្យប្រជាពលរដ្ឋចំនួន ៥៧៤ គ្រួសារ ត្រូវបានអនុប្រធានបរិស្ថានគីរីរម្យរំលោភយកដោយមានការជ្រោមជ្រែងពីយោធានៃកងយោធពលខេមរភូមិន្ទម្នាក់ ដែលបានធ្វើឱ្យរបួស និងបាញ់បុរស ៣ នាក់ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ |
| PA | ថ្ងៃទី២៩ ខែមេសា | បុរសម្នាក់អាយុ ២៧ ឆ្នាំ ត្រូវរងរបួសដោយយោធានៃកងយោធពលខេមរភូមិន្ទម្នាក់ ។ ប៉ុន្តែគាត់បានរត់គេចខ្លួន បន្ទាប់មកមេបញ្ជាការ វរសេនាតូចនៃកងរថក្រោះលេខ ៦២ បានបាញ់គាត់ ហើយមូលហេតុមកពីបញ្ហាពាក់ព័ន្ធនឹងទំនាស់ដីធ្លី នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ |
| DAP<br>PA | ថ្ងៃទី០៥ ខែឧសភា | យោធាកងពលតូចលេខ ៣១ ម្នាក់ និងទាហានពីរនាក់ទៀត ព្រមទាំងកូនប្រុសរបស់មេបញ្ជាការរងវរសេនាធំលេខ ៣១ ម្នាក់ទៀត បានបាញ់ស្ត្រី២ នាក់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពេលកំពុងរំលោភយកដីនៅស្រុកកំពង់សីលា ខេត្តកោះកុង ។ |
| LG | ថ្ងៃទី២៤ ខែឧសភា | ប្រជាពលរដ្ឋ ៥២ គ្រួសារ ត្រូវបានគំរាមកំហែងដោយកងកម្លាំងចម្រុះ រួមមានកងយោធពលខេមរភូមិន្ទ ដឹកនាំដោយ អភិបាលរងក្រុង នៅក្នុងការប៉ុនប៉ងរំលោភយកដីស្រែរបស់ប្រជាពលរដ្ឋនៅស្រុកសាលាក្រៅ ខេត្តប៉ៃលិន ។ |
| LG | ថ្ងៃទី២៥ ខែឧសភា | ដីមួយកន្លែងជារបស់ប្រជាពលរដ្ឋ ២ គ្រួសារ ត្រូវបានអាជ្ញាធរមូលដ្ឋានរំលោភយក ហើយក្រោយមកបានលក់ទៅឱ្យមេបញ្ជាការ |

| | | |
|---|---|---|
| | | រងយោធា ក្នុងស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។ |
| DAP FE | ថ្ងៃទី២០ ខែមិថុនា | ដីស្រែប្រើប្រាស់ដោយប្រជាពលរដ្ឋ ៨៧ គ្រួសារ ត្រូវបានយោធាកងវិស្វកម្ម លេខ៣០ នាក់រំលោភយកក្រោមបញ្ជារបស់អភិបាលរងខេត្ត ដើម្បីធ្វើជា "ដីសម្បទានសង្គមកិច្ច" សម្រាប់យោធិនពិការ នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ |
| FE | ថ្ងៃទី២៩ ខែមិថុនា | យោធាកងពលតូចលេខ ៣១ បានបណ្ដេញប្រជាពលរដ្ឋ ២០០ គ្រួសារ ដោយហិង្សា ដែលរស់នៅក្បែរ "សម្បទានដីសង្គមកិច្ច" អភិវឌ្ឍន៍សម្រាប់យោធិនពិការនៅស្រុកឈូក ខេត្តកំពត ។ ក្នុងពេលបណ្ដេញនោះ ប្រជាពលរដ្ឋ ៤ នាក់ត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបញ្ជូនទៅឃុំឃាំងនៅពន្ធនាគាររង់ចាំការបើកសវនាការ ។ |
| LG | ថ្ងៃទី១៨ ខែកក្កដា | ដីស្រែទំហំ ៤០ ហិកតា ជារបស់ប្រជាពលរដ្ឋ ២០ គ្រួសារ ត្រូវបានរំលោភយកដោយយោធាកងកាំភ្លើងធំ ដែលអះអាងថា គេត្រូវការដីនោះដើម្បីសាងសង់បន្ទាយយោធា នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ |
| DAP | ថ្ងៃទី២៧ ខែកក្កដា | ត្រាក់ទ័រមួយគ្រឿងជារបស់បុរសម្នាក់អាយុ ៤៧ ឆ្នាំ ត្រូវបានយោធាអង្គភាពយោធាអភិវឌ្ឍន៍ភូមិភាគ ៥ រឹបអូសយក ដោយបានចោទប្រកាន់ជនរងគ្រោះថា បានភ្ជួរដីរបស់យោធា នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ |
| LG | ថ្ងៃទី១៥ ខែសីហា | ដីស្រែរបស់ស្ត្រីម្នាក់អាយុ ២៥ ឆ្នាំ ត្រូវបានពាណិជ្ជករម្នាក់នៅក្នុងតំបន់ នោះរឹបអូសយក ហើយលក់ទៅឱ្យយោធាកងយោធពលខេមរភូមិន្ទ ។ ក្រោយមកយោធានោះ បានគម្រាមជនរងគ្រោះ នៅពេលយោធានោះ ប៉ុនប៉ងរុះរបងចេញនៅលើដីទំនាស់ នៅស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង ។ |
| LG | ថ្ងៃទី២៦ ខែសីហា | ដីទំហំ ៤០០ ហិកតា ជារបស់ប្រជាពលរដ្ឋ ១៥៤ គ្រួសារ ត្រូវហ៊ុំព័ទ្ធទុកឱ្យក្រុមហ៊ុន ភាពីម៉ិច ដោយយោធាកងវរសេនាតូចលេខ ១៤១ នៅស្រុកភ្នំ កវាញ ខេត្តពោធិ៍សាត់ ។ |
| DAP LG | ថ្ងៃទី៣១ ខែសីហា | យោធា ១៤ នាក់មកពីកងពលតូចលេខ ៣១ បំផ្លាញស្រែ និងដំណាំរបស់ប្រជាពលរដ្ឋ ២៨ គ្រួសារ និងរំលោភយកដី នៅស្រុកឈូក ខេត្តកំពត ដោយមានការឯកភាពពីអភិបាលខេត្ត ។ |
| DAP | ថ្ងៃទី២៤ ខែកញ្ញា | ផ្ទះរបស់ប្រជាពលរដ្ឋចំនួន ៦៣ គ្រួសារ ដែលត្រូវបានអាជ្ញាធរចោទប្រកាន់ថារស់នៅលើដីរដ្ឋខុសច្បាប់ ត្រូវបានដុតបំផ្លាញដោយ |

| | | |
|---|---|---|
| | | កងរាជអាវុធហត្ថ និងយោធានៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីរុក្ខាប្រមាញ់ នៅស្រុកវ៉ារិន្ទ ខេត្តសៀមរាប ។ |
| PA | ថ្ងៃទី២៤ ខែកញ្ញា | យោធាភូមិភាគ ៥ បានវាយបំបែកការតវ៉ារបស់ប្រជាពលរដ្ឋដោយហិង្សា ដែលប្រជាពលរដ្ឋទាំងនោះ គឺជាមនុស្សក្នុងចំណោម ៧៣ គ្រួសារ ដែលរងការប៉ះពាល់ដោយការរំលោភយកដីធ្លី នៅស្រុកសំឡូត ខេត្តបាត់ដំបង ។ យោធា ភូមិភាគ ៥ ម្នាក់បានបាញ់ក្មេងប្រុសជំទង់ម្នាក់ អាយុ ១៦ ឆ្នាំ ត្រូវចំពោះស្លាប់ ។ |
| LG | ថ្ងៃទី១០ ខែតុលា | មេបញ្ជាការរងកងពលតូច លេខ ៥៣ អមដោយយោធា ៦ នាក់ កាន់កាំភ្លើងគ្រប់ដៃ គំរាមកំហែងបុរសម្នាក់អាយុ ៥៥ ឆ្នាំ នៅពេលយប់ ក្នុងគោលបំណងដើម្បីរំលោភយកដីគាត់ នៅស្រុកសំពៅលូន ខេត្តបាត់ដំបង ។ |
| IAD | ថ្ងៃទី២៤ ខែតុលា | ប្រជាពលរដ្ឋ ៤ នាក់ ត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារឃុំឃាំងបណ្តោះ អាសន្នរង់ចាំការបើកសវនាការ ក្រោយពីបានធ្វើជាតំណាងប្រជាពលរដ្ឋ ៤០ គ្រួសារ ដែលប្រឈមមុខនឹងការរំលោភយកដីធ្លី ដោយមេបញ្ជាការរងយោធាខេត្តសៀមរាប នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ |
| DAP | ថ្ងៃទី០១ ខែវិច្ឆិកា | យោធាកងយោធពលខេមរភូមិន្ទខេត្ត បានកំទេច និងដុតផ្ទះ៧ខ្នងដោយខុសច្បាប់ និងគំរាមកំហែងប្រជាពលរដ្ឋដោយបង្ខំ ១៦២ គ្រួសារ ឱ្យចាកចេញពីដីរបស់រដ្ឋ នៅខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ |
| DAP<br>FE | ថ្ងៃទី១៧ ខែវិច្ឆិកា | កងកម្លាំងចម្រុះមួយក្រុម ដឹកនាំដោយយោធាកងពលតូចលេខ ៣១ បានបំផ្លិចបំផ្លាញ និងដុតទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ៣០០ គ្រួសារ នៅក្នុងការប៉ុនប៉ងមួយ ដើម្បីបណ្តេញប្រជាពលរដ្ឋទាំងនោះចេញពីដីដោយបង្ខំ នៅស្រុកឈូក ខេត្តកំពត ។ |
| DAP<br>LG | ថ្ងៃទី១៩ ខែវិច្ឆិកា | យោធានៃអង្គភាពអភិវឌ្ឍន៏កងយោធពលខេមរភូមិន្ទខេត្ត ២ នាក់ បំផ្លាញស្រូវនៅលើដីរបស់ប្រជាពលរដ្ឋ ១៥៦គ្រួសារ ដែលដីនោះទាមទារដោយមេបញ្ជាការយោធាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ |
| LG | ថ្ងៃទី២១ ខែវិច្ឆិកា | ដីទំហំ ៤៤១ ហិកតា ជារបស់ប្រជាពលរដ្ឋ ៣៣៨ គ្រួសារ ដែលភាគច្រើន ជាអតីតយោធាខ្មែរក្រហម ដែលបានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល នៅចុងទសវត្សរ៍ ៩០ ត្រូវបានទាមទារយកដោយមេបញ្ជាការរងយោធាអង្គភាពលេខ ៥១ នៃផ្នែកសឹករង និងយោធា នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ |

**សំគាល់:** តារាងនេះ ដាក់បញ្ចូលតែករណីណាដែលការិយាល័យលីកាដូបានស៊ើបអង្កេតប៉ុណ្ណោះ (នៅក្នុងខេត្ត-ក្រុង ចំនួន ១៣)។ មិនបានដាក់បញ្ចូលនូវករណីមួយចំនួនដែលកើតឡើងនៅខេត្តផ្សេងៗទៀត ដែលមានវត្តមានយោធានៅទីនោះទេ (ដូចជា ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ ជាដើម) ជាខេត្ត ដែលលីកាដូ ពុំមានការិយាល័យនៅទីនោះ។

## ករណីសិក្សា : តាកែន ខេត្តកំពត



*ទាហានយាមច្រកចេញ-ចូលអន្លង់ក្រោម ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨*

ក្នុងឆ្នាំ២០០៨ សហគមន៏មួយនៅឃុំតាកែន នៅស្រុកឈូក បានស៊ូទ្រាំនឹងការចោទប្រកាន់ និងបណ្តេញចេញដោយបង្ខំពីលំនៅឋានអស់រយៈពេលមួយឆ្នាំ ពីសំណាក់កងកម្លាំងយោធា ដឹកនាំដោយកងពលតូចលេខ ៣១ នៃកងយោធពលខេមរភូមិន្ទ។ បញ្ហាជម្លោះដីធ្លីនោះ បានចាប់ផ្តើមកាលពីខែមីនា ពេលដែលយោធាកងពលតូចលេខ ៣១ រឹបអូសយកដីរបស់សហគមន៏ដែលមានសមាជិកចំនួន ១៥២ គ្រួសារ នៅភូមិជ័យសេនា។ គេបានប្រាប់ប្រជាពលរដ្ឋ ទាំងនោះថា គេត្រូវការដីដើម្បីកសាងផ្លូវទៅកន្លែងមួយដែលគេហៅថា "ដីសម្បទានសង្គមកិច្ច" សម្រាប់គ្រួសារយោធិនពិការ ដែលជួយឧបត្ថម្ភដោយលោកជំទាវប៊ុន រ៉ានី ហ៊ុន សែន និងឧត្តមសេនីយ គន់ គីម អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ។ ការប្រឈមមុខដាក់គ្នាបានកើតឡើង ដោយយោធាបានគំរាមអ្នកភូមិ និងបាញ់កាំភ្លើងលើក្បាលប្រជាពលរដ្ឋទាំងនោះ បណ្តាលឱ្យស្រ្តីមានជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរម្នាក់ ត្រូវរងរបួស។ ដោយខ្លាចមានផលវិបាកទៅថ្ងៃមុខទៀត ទីបំផុតគ្រួសារទាំងនេះបានយល់ព្រមប្រគល់ដីមួយចំនួនឱ្យទៅយោធានោះ។

នៅខែមិថុនា ស្ថានភាពនៅទីនោះ កាន់តែធ្ងន់ធ្ងរជាទីបំផុត ដែលពេលនោះអ្នកឃ្លាំមើលសិទ្ធិមនុស្សបានទទួលព័ត៌មានថា ប្រជាពលរដ្ឋជាង ២០០ គ្រួសារ នៅភូមិជ័យសេនា ដែលរស់នៅក្បែរ "ដីសម្បទានសង្គមកិច្ច" កំពុងប្រឈមការបណ្តេញចេញពីលំនៅឋាន ដោយកងកម្លាំងចម្រុះ ដឹកនាំដោយកងពលតូចលេខ ៣១ ព្រមទាំងមានមន្ត្រីកងរាជអាវុធហត្ថ និងមន្ត្រីរដ្ឋបាលព្រៃឈើចូលរួមផងដែរ។ អ្នកឃ្លាំមើលសិទ្ធិមនុស្សបានធ្វើដំណើរទៅកាន់តំបន់នោះ ហើយបានត្រឹមតែជួបប្រទះឃើញគ្រប់ផ្លូវទាំងអស់ចូលទៅកាន់ភូមិជ័យសេនា ត្រូវពួកយោធាបិទដោយខុសច្បាប់។ រហូតដល់មួយសប្តាហ៏ក្រោយ ទើបក្រុមសិទ្ធិមនុស្សកម្ពុជា ត្រូវបានអនុញ្ញាតឱ្យចូលតំបន់នោះ អមដំណើរដោយការិយាល័យឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្រោមការឃ្លាំមើលយ៉ាងជិតដិតរបស់យោធាកងពលតូចលេខ ៣១ ហើយបានត្រឹមតែរកឃើញថា ការបណ្តេញប្រជាពលរដ្ឋចេញនោះបានបញ្ចប់អស់ទៅហើយ។

ពួកយោធាដែលប្រដាប់ដោយអាវុធគ្រប់ដៃនោះ បានប្រាប់ទៅប្រជាពលរដ្ឋនៅទីនោះថា ផ្ទះសម្បែង និងទ្រព្យសម្បត្តិទាំងអស់ត្រូវបំផ្លាញចោល ប្រសិនបើគេរឹងទទឹងមិនចាកចេញ ឬ ត្រូវបង់ថវិកាឱ្យពួកយោធាដឹកជញ្ជូនទ្រព្យសម្បត្តិទៅទីតាំងថ្មី ដែលមានចម្ងាយ ១០ គីឡូម៉ែត្រ ដោយប្រើប្រាស់រថយន្តដឹកជញ្ជូន ដែលជាជំនួយយោធារបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ផ្តល់ដល់កងយោធពលខេមរភូមិន្ទ។



*អ្នកភូមិអន្លង់ក្រោម ផ្ទះរបស់គាត់ត្រូវបានគេដុតបំផ្លាញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ (រូបភាពដោយ Courtesy of Hallam Goad)*

ក្រៅពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ បុរស ៣ នាក់ និងស្រ្តីម្នាក់ត្រូវបានចាប់ខ្លួនក្នុងពេលបណ្តេញនោះ ហើយបញ្ជូនទៅពន្ធនាគារខេត្តកំពត ។ បន្ទាប់ពីជាប់ពន្ធនាគាររង់ចាំការបើកសវនាការប្រហែលកន្លះឆ្នាំមក គេបានលើកលែងការចោទប្រកាន់បុរសទាំង ៣ នាក់ ហើយស្រ្តីម្នាក់នោះត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ ចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។

នៅខែវិច្ឆិកា មានព្រឹត្តិការណ៍កើតឡើងស្រដៀងគ្នានេះដែរ ពេលដែលកម្លាំងចម្រុះដឹកនាំដោយកងពលតូចលេខ ៣១ ដដែល បង្ខំប្រជាពលរដ្ឋចំនួន ២៧៨ គ្រួសារ ចេញដោយបង្ខំ ពីភូមិអន្លង់ក្រោម។ ជាថ្មីម្តងទៀត ពួកយោធាបានបិទផ្លូវទាំងអស់ចេញចូលទៅតំបន់នោះ ថែមទាំងមិនអនុញ្ញាតឱ្យអង្គការសិទ្ធិមនុស្ស និងក្រុមពេទ្យចូលទៅកន្លែងនោះបានទៀតផង គឺបានត្រឹមតែឃើញផ្សែងហុយចេញពីការដុតផ្ទះនៅក្នុងភូមិ។ ប្រជាពលរដ្ឋចំនួន ៥ នាក់ ត្រូវបានរងរបួស ហើយ ៣ នាក់ ត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យ ម្នាក់ត្រូវដេរជាង ១០ថ្នេរ នៅលើក្បាលបន្ទាប់ពីត្រូវបានវាយដំដោយដំបង និងស្ទ័យកាំភ្លើង ម្នាក់ទៀតបាក់ធ្មេញ និងជាំជាច្រើនកន្លែងនៅលើជើង ហើយអ្នកទី៣ រងរបួសចំដើមទ្រូងបណ្តាលមក ពីការវាយដំយ៉ាងធ្ងន់ធ្ងរ។

ដូចនៅភូមិជ័យសេនាដែរ ពួកយោធាទាំងនោះមិនបានបង្ហាញបទបញ្ជាបណ្តេញចេញដោយស្របច្បាប់ណាមួយទេ ឬ ផ្តល់ដំណឹងនៃការបណ្តេញចេញជាមុនដល់ប្រជាពលរដ្ឋឡើយ។ អាជ្ញាធរបានអះអាងថា ដីទំនាស់នោះគឺជាដីព្រៃការពាររបស់រដ្ឋ ដែលប្រជាពលរដ្ឋគ្មានសិទ្ធិរស់នៅលើដីនោះទេ។ ប៉ុន្តែដីទំនាស់នោះ

មិនឃើញមាននៅក្នុងផែនទីជាផ្លូវការនៃតំបន់ព្រៃការពារឡើយ ហើយជាធម្មតា យោធាកម្ពុជាក៏មិនមែនជាអ្នកប្តូរផ្តាច់ក្នុងការការពារព្រៃឈើកម្ពុជាដែរ ។ ដូច្នេះ ដីទំនាស់នោះ គួរតែជាដីទំនេរគ្មានអ្នកណាម្នាក់អាចប៉ះពាល់បានឡើយ[៤១] ។

□□□

[៤១] សូមមើល ឧទាហរណ៍ http://www.mekong-protected-areas.org/cambodia/maps/pas/gif តាកែន ស្ថិតនៅចន្លោះ (ប៉ុន្តែខាងក្រៅ) តំបន់ការពារសួនឧទ្យានជាតិបូកគោ និងគីរីរម្យ ។

# សេចក្តីសន្និដ្ឋាន

គោលនយោបាយ និងការអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងដីធ្លី បានទទួលការបរាជ័យ។ មិនត្រឹមតែមិនបានរួមចំណែកជាវិជ្ជមានក្នុងការអភិវឌ្ឍប្រទេសជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង

***"ដៃគូរបស់យើង ត្រូវតែសម្រេចបានលទ្ធផលដ៏ធំធេង***
***សម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសអ្នកក្រីក្រ***
***និងអ្នកងាយរងគ្រោះ"***

គីមីវ ហ្វាន់ ប្រធានធនាគារពិភពលោកសម្រាប់កម្ពុជា
ឆ្នាំ២០០៨[៤២]

បង្កឱ្យមានប្រជាពលរដ្ឋគ្មានដីធ្លី គ្មានការងារ ព្រមទាំងមានភាពក្រីក្រថែមទៀត។ អាជ្ញាធរកម្ពុជា ហាក់ដូចជាមិនអាច ឬ គ្មានឆន្ទៈគោរពច្បាប់ អនុក្រិត្យ និងបទបញ្ញត្តិនានា របស់ខ្លួនសោះ ហើយមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានឃុបឃិតជាមួយអ្នកមានអំណាច និងក្រុមហ៊ុនមួយចំនួន រំលោភយកដីប្រជាពលរដ្ឋទៀត។ ការរំលោភសិទ្ធិមនុស្ស គឺជាអំពើរាលដាលពាសពេញក្នុងប្រទេសកម្ពុជា នាសម័យថ្មីនេះ ដោយមានតាំងពីការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ រហូតដល់បង្ករបួសស្នាម ការចាប់ និង ឃុំខ្លួនខុសច្បាប់ ហើយរហូតដល់មានការសម្លាប់ថែមទៀតផង។

បច្ចុប្បន្ន សហគមន៍ជាច្រើន កំពុងរស់នៅពោរពេញទៅដោយការភ័យខ្លាចពីការបណ្តេញចេញ ការបាត់បង់លំនៅឋាន និងជីវភាពរស់នៅ ហើយធ្លាក់ចូលក្នុងភាពក្រីក្រកាន់តែទាបបំផុត។ តាមមើលទៅប្រជាពលរដ្ឋទាំងនោះ ប្រាកដជាមិនអាចមានលទ្ធភាពរស់នៅក្នុងសំណង់ផ្ទះល្វែងល្អៗ ឬចូលទិញទំនិញនៅក្នុងហាងទំនើបៗ ដែលសាងសង់នៅលើដីរបស់ពួកគេបានទេ ប្រសិនបើការអភិវឌ្ឍបែបនោះ អាចកើតមានឡើងប្រាកដមែន។ គម្រោងបណ្តេញប្រជាពលរដ្ឋនៅបឹងកក់ចំនួន ៤,២៥២ គ្រួសារ ដែលជិតនឹងកើតឡើងក្នុងពេលឆាប់ៗនេះ អាចជាការបង្ខំឱ្យទៅរស់នៅកន្លែងតាំងទីលំនៅថ្មីមួយយ៉ាងធំ ពីរាជធានីភ្នំពេញ ក្រោយ

[៤២] បទសង្កេតការណ៍បិទកម្មវិធី នៃ វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ។

ពីការដួលរលំនៃរបបខ្មែរក្រហមដែលត្រួតត្រាទីក្រុងនេះនៅឆ្នាំ១៩៧៩។ តួលេខនៃការបណ្តេញចេញពីលំនៅឋានខាងលើ ពិបាកនឹងកោតសរសើរដល់រាជរដ្ឋាភិបាលបច្ចុប្បន្នខ្លាំងណាស់។

អាកប្បកិរិយារបស់រាជរដ្ឋាភិបាល មើលទៅដូចជាគិតថា ប្រជាពលរដ្ឋនៅសហគមន៍ក្រីក្រទាំងនោះ មិនមានសមត្ថភាពចូលរួមក្នុងការអភិវឌ្ឍបានឡើយ ដូច្នេះហើយត្រូវតែប្រគល់ដីរបស់ខ្លួនឱ្យទៅក្រុមហ៊ុនឯកជន ដែលធានាថាមានលទ្ធភាពក្នុងការអភិវឌ្ឍនោះ។ ប៉ុន្តែផ្ទុយទៅវិញ យោងតាមការសិក្សា និងស្រាវជ្រាវជាច្រើន បានបង្ហាញឱ្យដឹងថា បើផ្តល់ឱកាសឱ្យពួកគេ នោះសហគមន៍កម្ពុជានានា គឺមានលទ្ធភាពយ៉ាងពេញលេញក្នុងការគ្រប់គ្រងដីរបស់ខ្លួនបានដោយប្រសិទ្ធិភាព ហើយឈានដល់អាចមានគំនិតច្នៃប្រឌិតបង្កើតដៃគូជាមួយក្រុមហ៊ុនធំៗនានា ដើម្បីរកចំណូល និងអភិវឌ្ឍន៍ថែមទៀតផង[៤៣]។

គោលបំណងក្នុងការកសាងសហគមន៍ឱ្យបានរឹងមាំបែបនេះជាច្រើន មិនអាចកើតឡើងបានទេ ព្រោះវាត្រួតគ្នាជាមួយនឹងផែនការ "អភិវឌ្ឍន៍" ធំៗ ដូចជាដំណើរការគ្រប់គ្រងជីរួមគ្នានៅខេត្តកោះកុង ដែលគិតថាគ្មានប្រយោជន៍ ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីដាំអំពៅ ឬ គម្រោង អេកូទេសចរណ៍ជនជាតិដើមភាគតិចនៅខេត្តកំពង់ស្ពឺ ដែលត្រូវបានឈប់ទៅវិញ ក្រោយពេលផ្តល់សម្បទានទេសចរណ៍ជំនួញធំៗមួយ នៅកន្លែងតែមួយនោះ[៤៤]។ ហើយដំណោះស្រាយបញ្ហាអភិវឌ្ឍន៍នៅកម្ពុជា គឺមានរួចជាស្រេចហើយ ដែលជ្រើសរើសដោយមន្ត្រីរាជរដ្ឋាភិបាលទាំងអស់ធ្វើការ "អភិវឌ្ឍន៍" ច្រើនតែធ្វើឱ្យប្រជាពលរដ្ឋធម្មតារងគ្រោះ។

ប្រសិនបើរដ្ឋាភិបាលពិតជាខ្វាយខ្វល់អំពីការកាត់បន្ថយភាពក្រីក្រមែននោះ ត្រូវតែចាត់វិធានការ ជាបន្ទាន់ ដោយសហការជាមួយប្រជាពលរដ្ឋរបស់ខ្លួន ដោយមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់សហគមន៍អន្តរជាតិ ដើម្បីចាប់ផ្តើមអនុវត្តឱ្យចេញផ្លែផ្កាជាក់ស្តែងសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះពិត

---

[៤៣] សូមមើលឧទាហរណ៍ របាយការណ៍របស់ Fox McMahon, Poffengberger and *Vogler* *ដីរបស់ចៅខ្ញុំ : ការប្រើប្រាស់ និងកាន់កាប់ដីមានការផ្លាស់ប្តូរ នៅខេត្តរតនគិរី ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ២០០៧។ សហគមន៍ព្រៃឈើអន្តរជាតិ និងមជ្ឈមណ្ឌលបូពាំ-បស្ទឹម ឆ្នាំ២០០៨ ជាឧទាហរណ៍ ចំពោះផែនការប្រើប្រាស់យូរអង្វែង និងជោគជ័យ ដោយសហគមន៍ជនជាតិដើមភាគតិច*។ សូមអានផងដែររបាយការណ៍របស់ Bolster and Brimble *កម្ពុជាៈ ការទទួលខុសត្រូវសង្គម និងគំនិតផ្តួចផ្តើមពាណិជ្ជកម្មកម្ពុជា ក្នុងវិស័យអភិវឌ្ឍន៍ជនបទ (C-BIRD) ២០០៨*។ ជាឧទាហរណ៍ នៃការសហប្រតិបត្តិការ ដៃគូសហគមន៍។

[៤៤] ទស្សនៈសិទ្ធិមនុស្សៈ *សម្បទានដីសេដ្ឋកិច្ច នៅកម្ពុជាៈ* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧។

ប្រាកដ។ សម័យនេះ គឺជាពេលសម្រាប់រដ្ឋាភិបាលហ៊ានក្រោកឈរឡើងប្រឈមនឹងការពិតក្នុងការអភិវឌ្ឍ នៅកម្ពុជា ដោយមិនត្រូវនៅតែបន្តការអភិវឌ្ឍក្លែងក្លាយតទៅទៀតទេ។

□□□

# អនុសាសន៍

អនុសាសន៍ជាច្រើនដើម្បីចាត់វិធានការដោះស្រាយវិបត្តិដីធ្លីនៅកម្ពុជា ត្រូវបានលើកឡើងម្តងហើយម្តងទៀតក្នុងការតស៊ូមតិ ដើម្បីអភិវឌ្ឍន៍ផ្នែកសិទ្ធិមនុស្ស និងច្បាប់។ អង្គការលីកាដូនៅតែរក្សា សារៈសំខាន់នៃអនុសាសន៍ទាំងនេះ រួមទាំងអនុសាសន៍ស្នើឱ្យរាជរដ្ឋាភិបាលប្រកាសផ្អាកការបណ្តេញប្រជាពលរដ្ឋដែលមិនស្ម័គ្រចិត្តចេញ ហើយស្នើឱ្យរាល់សម្បទានដីសេដ្ឋកិច្ចទាំងអស់ត្រូវផ្អាកដំណើរការសិន រង់ចាំការត្រួតពិនិត្យឡើងវិញឱ្យត្រឹមត្រូវតាមច្បាប់ និងផលប៉ះពាល់លើដីសហគមន៍ទាំងនោះឱ្យបានត្រឹមត្រូវសិន។ លើសពីនេះទៅទៀត នៅមានអនុសាសន៍ជាច្រើនពិស្តារថែមទៀតដែលលើកឡើងកាលពីពេលមុន ជូនរាជរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ[៤៥] ។ អង្គការលីកាដូ សូមផ្តល់អនុសាសន៍ ដល់រដ្ឋាភិបាលដើម្បីចាត់វិធានការដូចខាងក្រោមៈ

ដើម្បីបង្ហាញនូវការសន្យាពិតប្រាកដរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសម្រាប់ប្រជាពលរដ្ឋកម្ពុជា និងដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ព្រមទាំងជាមួយសហគមន៍អន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាគួរតែៈ

---

[៤៥] រួមមានអនុសាសន៍ដែលលើកឡើងចំពោះៈ សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា។ ទស្សនៈសិទ្ធិមនុស្សៈ *ដីសម្បទាននៅកម្ពុជាៈ* តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែមិថុនា ឆ្នាំ២០០៧ មាននៅក្នុងគេហទំព័រៈ http://cambodia.ohchr.org/EN/report_thematic.htm *លំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅគ្រប់គ្រាន់* របាយការណ៍របស់អ្នកនាំពាក្យពិសេស លោក មីលូន កាថារីៈ ក្នុងបេសកកម្មរបស់លោកនៅកម្ពុជា ខែមីនា ឆ្នាំ២០០៦ មាននៅក្នុងគេហទំព័រ : http://daccessdds.un.org/doc/UNDOC/GEN/G06119/37/PDF/G0611937.pdf?OpenElement; អង្គការលើកលែងទោសអន្តរជាតិៈ *សិទ្ធិមនុស្សត្រូវបានបំផ្លាញចោលក្នុងការបណ្តេញចេញពីលំនៅឋាននៅកម្ពុជា* ខែកុម្ភៈ ឆ្នាំ២០០៨ មាននៅក្នុងគេហទំព័រ : http://www.amnestyusa.org/document.php?id=ENGASA230022008&lag+e; ក្រុមការងារស្តីពីដីធ្លី និងលំនៅដ្ឋាននៅកម្ពុជាៈ *សិទ្ធិដីធ្លី និងលំនៅឋាននៅកម្ពុជា របាយការណ៍ស្របគ្នា ឆ្នាំ២០០៩* ខែមេសា ឆ្នាំ២០០៩ មាននៅក្នុងគេហទំព័រៈ
http://www.cohchr.org/store/attachments/Land%20and%and%20Housing%Rights%20in%20Cambodia%20(final).pdf

១. អនុវត្តតាមមាត្រា ១៤៧-១៤៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលកន្លងមកត្រូវបានបំភ្លេចចោល ដែលតម្រូវឱ្យមានការធ្វើសមាជជាតិប្រចាំឆ្នាំ ក្រោមព្រះរាជអធិបតេយ្យភាពនៃព្រះមហាក្សត្រ ដែលសាធារណជនទូទៅ និងរដ្ឋាភិបាលអាចពិភាក្សាគ្នា អំពីបញ្ហាប្រទេសជាតិសំខាន់ៗ និងលើកឡើងនូវអនុសាសន៍នានាដើម្បីដោះស្រាយ។ បញ្ហាដីធ្លី ត្រូវតែផ្តល់អាទិភាពជាចម្បងដើម្បីពិភាក្សានៅក្នុងសមាជជាតិនោះ។

២. អញ្ជើញមន្ត្រីដូចមានរាយនាមខាងក្រោម ដែលមន្ត្រីទាំងនោះសុទ្ធតែជាមន្ត្រីអង្គការសហប្រជាជាតិ ទទួលបន្ទុកក្នុងការអនុវត្តនីតិវិធីសំខាន់ៗ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីមកធ្វើទស្សនកិច្ចនៅកម្ពុជា ដើម្បីធ្វើការពិភាក្សាដោយស្មោះត្រង់ជាមួយអ្នកជំនាញទាំងនេះ ក្នុងស្មារតីសហប្រតិបត្តិការទៅវិញទៅមក អំពីការអភិវឌ្ឍនៅកម្ពុជា ព្រមទាំងបញ្ហាលំនៅឋាន និងដីធ្លី ជាដើម។

- អ្នកស្រី Raquel Rolnik អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពសមរម្យ និងស្តីពីសិទ្ធិ គ្មានការរើសអើងនៅក្នុងបរិបទនេះ។
- អ្នកស្រី Maria Magdalena Sepulveda Carmona អ្នកជំនាញឯករាជស្តីពី បញ្ហាសិទ្ធិមនុស្ស និងភាពក្រីក្រ។
- លោក Anand Grover អ្នករាយការណ៍ពិសេសស្តីពី សិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបាននូវបទដ្ឋានសុខភាព ផ្លូវកាយ និងផ្លូវចិត្ត។
- អ្នកស្រី Catarina de Albuquerque អ្នកជំនាញឯករាជស្តីពីបញ្ហាកាតព្វកិច្ចសិទ្ធិមនុស្ស ទាក់ទងនឹងទឹកស្អាត និងអនាម័យ។
- លោក Olivier De Schutter អ្នករាយការណ៍ពិសេសស្តីពី សិទ្ធិមានម្ហូបអាហារ។
- លោក Vernor Munoz Villalobos អ្នករាយការណ៍ពិសេសស្តីពី សិទ្ធិក្នុងការអប់រំ។

- លោក James Anaya អ្នករាយការណ៍ពិសេសស្តីពី ស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន របស់ជនជាតិដើមភាគតិច[៤៦] ។

សហគមន៍ផ្តល់ជំនួយអន្តរជាតិ ត្រូវតែទទួលស្គាល់ថា អសន្តិសុខក្នុងបញ្ហាដីធ្លី គឺជាការរារាំងមួយ ដែលមានការពាក់ព័ន្ធយ៉ាងខ្លាំងជាមួយការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍ជាមូលដ្ឋានផ្សេងៗទៀត:

១. ផ្អាកបណ្តោះអាសន្ននូវជំនួយហិរញ្ញវត្ថុឱ្យរាជរដ្ឋាភិបាលកម្ពុជា រហូតដល់ពេលណាមួយដែលរាជរដ្ឋាភិបាល អាចបង្ហាញនូវការសន្យាពិតប្រាកដ ដើម្បីដោះស្រាយវិបត្តិដីធ្លី រួមទាំងការប្រកាសផ្អាកការបណ្តេញ ប្រជាពលរដ្ឋចេញពីលំនៅឋានដោយបង្ខំ និងផ្អាកជាបណ្តោះអាសន្ននូវសម្បទានដីសេដ្ឋកិច្ចទាំងអស់ ។

២. បង្កើតវេទិកាជួបប្រជុំប្រចាំត្រីមាសជាមួយអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ និងសមាជិកសង្គមស៊ីវិលនានា ដែលធ្វើការយ៉ាងសកម្មនៅតាមសហគមន៍ និងជាអ្នកទទួលបានព័ត៌មានផ្ទាល់អំពីស្ថានភាពដីធ្លី និងករណីរំលោភដីធ្លី ដើម្បីបង្កើនការចែករំលែកព័ត៌មាន ដែលអាចជួយដល់សហគមន៍អន្តរជាតិ ក្នុងការចូលរួមដោះស្រាយបញ្ហាទាំងអស់នេះ ជាមួយរាជរដ្ឋាភិបាលឱ្យកាន់តែប្រសើរជាងមុន ។

៣. ធ្វើអន្តរាគមន៍យ៉ាងសកម្ម ជាបុគ្គល និងរួមសហការគ្នា ក្នុងការជ្រើសរើសករណីរំលោភដីធ្លីសំខាន់ៗ ជាមួយអាជ្ញាធរកម្ពុជា ដើម្បីធានាឱ្យបាននូវការចរចារជាបន្តបន្ទាប់ជាមួយរាជរដ្ឋាភិបាល ដើម្បីប្រែក្លាយឱ្យមានការរីកចំរើនពិតប្រាកដ ។

---

[៤៦] តាំងពីដើមមក គ្មាននរណាម្នាក់ក្នុងចំណោមមន្ត្រីទាំងនេះធ្លាប់បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ជាផ្លូវការទេ ។ អ្នកកាន់ ដំណែងជាអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅឋានសមរម្យ មុនអ្នកស្រី Rolnik គឺ លោក មីលូន កាថារី បានអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជាកាលពីឆ្នាំ២០០៥ ។ សូមអានគេហទំព័រខាងក្រោមអំពី បញ្ជីឈ្មោះរបស់អ្នករាយការណ៍ពិសេស: http://www2.ohchr.org/english/issues/

http://www.licadho-cambodia.org/